ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ញត្តិនៃការធានាគុណភាពអប់រំ

# កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ

# នៅកម្ពុជា

ខែកុម្ភៈ ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១០១០ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តបញ្ញត្តិនៃការធានាគុណភាពអប់រំ កម្រិតមត្តេយ្យសិក្សា និងអប់រំចំណោះទូទៅនៅកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណោះទូទៅនៅកម្ពុជា។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៥

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច «ដើម្បីជ្រាបជាព័ត៌មាន»
- សាលារាជធានី ខេត្ត
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត «ដើម្បីសហការអនុវត្ត»
- ឯកសារកាលប្បវត្តិ ៖ នា.នីតិកម្ម

# បុព្វកថា

គុណភាពអប់រំជាកត្តាដ៏សំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ការអភិវឌ្ឍធនធានមនុស្ស ទាមទារធ្វើការត្រួតពិនិត្យ ការតាមដាន និងវាយតម្លៃជាប់ជាប្រចាំសំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ សេចក្តីណែនាំ គោលការណ៍ឲ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងវិធានការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា។

ឆ្លើយតបនឹងបរិបទខាងលើ និងបរិបទសកលភាវូបនីយកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា ក្នុងគោលបំណងកំណត់អំពីភារកិច្ច និងតួនាទីរបស់អធិការសម្រាប់ធ្វើអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីលើកកម្ពស់គុណភាពអប់រំឲ្យមានភាពឆ្លើយតប និងទទួលយកបានសម្រាប់ឈានចូលទៅសិក្សា នៅតាមសាលាមធ្យមសិក្សាឯកទេស គ្រឹះស្ថានឧត្តមសិក្សា និងក្នុងទីផ្សារការងារ។

បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា នឹងធានាឲ្យបាននូវការពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍទាំងអស់ ពិសេសអធិការដ្ឋានអប់រំ ប្រទេសស៊ុយអែតដែលបានជួយគាំទ្រទាំងស្មារតី សម្ភារៈ និងថវិកា ដើម្បីធ្វើឲ្យសម្រេចបាននូវបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជាសម្រាប់ជាត្រីវិស័យក្នុងការធានាគុណភាពអប់រំ។

ក្រសួងសង្ឃឹមថា ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ផ្នែកឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ គាំទ្រ និងអនុវត្តបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជាឲ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# មាតិកា
# បញ្ញត្តិនៃការធានាគុណភាពអប់រំ
# កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា


**១-សាវតារអប់រំ និងអធិការអប់រំនៅកម្ពុជា** ១

១.១-ការសិក្សានៅក្រោមអាណានិគមបារាំង ១

១.២-ការសិក្សាអប់រំពីឆ្នាំ ១៩៤៥-១៩៧៥ ១

១.៣-ការសិក្សាអប់រំពីឆ្នាំ ១៩៧៩ ដល់បច្ចុប្បន្ន ២

**២-សេចក្តីផ្តើម** ៤

**៣-ក្របខណ្ឌធានាគុណភាព** ៧

**៤-ឧបករណ៍អធិការកិច្ចសម្រាប់ធានាគុណភាព** ៩

៤.១-គោលបំណងនៃការធ្វើអធិការកិច្ច ៩

៤.២-តួនាទីអធិការ ១០

៤.៣-វិធីសាស្ត្រធ្វើអធិការកិច្ច ១១

៤.៤-ការផ្តល់យោបល់ និងណែនាំ ១២

៤.៥-ការអភិវឌ្ឍសមត្ថភាពអធិការ ១២

**៥-អធិការកិច្ចផ្ទៃក្នុង** ១២

៥.១-ស្វ័យវាយតម្លៃសាលារៀន ១៣

៥.២-ថ្នាក់ក្រុង ស្រុក ខណ្ឌ ១៥

**៦ -អធិការកិច្ចផ្ទៃក្រៅ** ១៦

៦.១-អធិការកិច្ចតាមប្រធានបទ ១៧

៦.១.១-ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមប្រធានបទ ១៩

៦.២-អធិការកិច្ចតាមកាលកំណត់ ២០

៦.២.១-ភាពញឹកញាប់នៃការធ្វើអធិការកិច្ចតាមកាលកំណត់ ២១

៦.២.២-ប្រពន្ធ័របាយការណ៍អធិការកិច្ចតាមកាលកំណត់ ២២

៦.២.៣-លទ្ធផលនៃដំណើកាតវាយតម្លៃ ២៣

៦.២.៤-ឧបករណ៍ដែលត្រូវបង្កើត ២៤

**៧-មូលដ្ឋានគតិយុត្តសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ច** ២៤

៧.១-រដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍អន្តរជាតិ ២៥

៧.២-ច្បាប់ស្តីពីការអប់រំ ២៥

៧.៣-យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ២៦

៧.៤-អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ២៧

៧.៥-ផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងឯកសារគោលនយោបាយដទៃទៀត ២៧

៧.៦-គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩ ២៨

៧.៧-កម្មវិធីសិក្សា ២៨

៧.៨-គ្រូបង្រៀន និងបុគ្គលិកអប់រំ ២៩

# បញ្ញត្តិនៃការធានាគុណភាពអប់រំ
# កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា

## ១-សាវតារអប់រំ និងអធិការកិច្ចអប់រំនៅកម្ពុជា

### ១.១-ការសិក្សានៅក្រោមអាណាព្យាបាលបារាំង

ការសិក្សានៅក្រោមអាណាព្យាបាលបារាំង(១៨៦៣-១៩៤៥)[1] គឺ៖ **ការសិក្សានៅសាលាបារាំង-ខ្មែរ ឬការសិក្សាជាផ្លូវការ និងការសិក្សាបែបប្រពៃណីកែប្រែថ្មី** ដែលក្នុងនោះការសិក្សា នៅសាលាបារាំង-ខ្មែរ ឬ **ការសិក្សាជាផ្លូវការមាន៖** (១)សាលានៅតាមឃុំ (២)សាលាបឋមសិក្សា ជាន់ដំបូង (៣)សាលាបឋមសិក្សាបំពេញវិជ្ជា (៤)សាលាបឋមសិក្សាជាន់ខ្ពស់និងមធ្យមសិក្សា បារាំង-ស្រុកអាយ មាន:បឋមសិក្សាជាន់ខ្ពស់ផ្នែកគរុវិជ្ជា និងមធ្យមសិក្សាទុតិយភូមិ (៥)ឧត្តម សិក្សា (៦)វិជ្ជាជីវសិក្សាមាន៖ សាលាបច្ចេកទេសនិងវិជ្ជាជីវៈ សាលាសិល្បៈខ្មែរ (៧)សាលារៀន ឯកជនមាន: សាលារៀនឯកជនបង្រៀនភាសាបារាំង សាលារៀនភាសាបារាំង និងភាសាអ្នកស្រុកអាយ សាលាបង្រៀនភាសាអ្នកស្រុកអាយ និងសាលាបង្រៀនភាសាបរទេស។ **រីឯការសិក្សាបែបប្រពៃណីកែប្រែថ្មីមាន ៖** ការបង្កើតសាលាអនុវត្ត ការបង្កើតសាលាអនុវត្តជាន់ខ្ពស់ និងបុគ្គលិកបម្រើការសិក្សាបែបប្រពៃណីកែប្រែថ្មី។

ក្នុងឆ្នាំ១៩៣៥ គ្រូបង្រៀនជាគ្រហស្ថ មួយចំនួនបានបម្រើការផ្នែកសិក្សាកែប្រែ។ ទន្ទឹមនិងនោះ ដើម្បីជួយក្នុងការពង្រឹងគុណភាពអប់រំ លោក **ម៉ានីពូដ៍** (Manipoud) ដែលជាព្រះរាជប្រតិភូរបស់ព្រះករុណាជីវិតលើត្បូង បានតែងតាំងលោក **អ៊ុំ ឈាងស៊ុន** ជាភ្នាក់ឈ្មួយទទួលបន្ទុកអធិការកិច្ចសាលាវត្តនៅភូមិភាគខាងត្បូង ដែលក្នុងនោះមានខេត្ត កំពត កណ្ដាល កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង តាកែវ និងរាជធានីភ្នំពេញ។ លោក **ចៃត្រ ឆែម** ជាភ្នាក់ឈ្មួយទទួលបន្ទុកអធិការកិច្ច សាលាវត្តភូមិភាគខាងជើង ដែលក្នុងនោះមានខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ក្រចេះ ពោធិសាត់ និងខេត្តសៀមរាប និងតែងតាំងលោក **ខិម ប៉ែន** ជាលេខាធិការ។ ក្រៅពីលោកទាំងបីនាក់នេះ មានគ្រូជាច្រើនទៀតបម្រើការសិក្សា កែប្រែក្នុងឋានៈជាអធិការរង មាន ១៦ នាក់ និងនាយកសាលាអនុវត្ត ១៤ នាក់។

នៅសម័យនោះ នាយកក្រសួងសិក្សាធិការត្រូវបានដឹកនាំដោយបុគ្គលិកបារាំងម្នាក់ហើយ នាយកនេះស្ថិតនៅក្រោមឱវាទរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់។ ចំណែកឯការសិក្សាវិញត្រូវអនុវត្តតាមបញ្ជាពីលោកអគ្គនាយកសិក្សាសាធារណៈនៅក្រុងហាណូយ ហើយនៅតាមខេត្តធំៗ នៃព្រះរាជាណាចក្រមានបុគ្គលិកសិក្សាបារាំងម្នាក់មានតួនាទីជាអធិការបឋមសិក្សា ក្នុងមួយឆ្នាំៗលោកអធិការនេះធ្វើទស្សនាចរទៅធ្វើអធិការកិច្ចនៅសាលាបឋមសិក្សាជាន់ដំបូងនៅតាមទីរួមស្រុក។ រីឯសាលាវត្តវិញគាត់មិនមានសិទ្ធិធ្វើអធិការកិច្ចទេ ពីព្រោះសាលាវត្ត សាលាអនុវត្ត នៅតាមខេត្តស្ថិតនៅក្រោមការគ្រប់គ្រងផ្សេង គឺតាមរយៈលោក **ម៉ានីពូដ៍** ដែលជាព្រះរាជប្រតិភូរបស់ព្រះករុណាជីវិតលើត្បូង។

### ១.២-ការសិក្សាអប់រំពីឆ្នាំ ១៩៤៥ ដល់ ១៩៧៥

នាសម័យនោះទីស្ដីការក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈត្រូវបានដឹកនាំដោយឥស្សរជនខ្មែរសុទ្ធសាធ។ នៅឆ្នាំ ១៩៤៧ នាយកដ្ឋានមួយត្រូវបានបង្កើតដែលចែកជាក្រុមសេវាកម្មពីរគឺ៖ ក្រុមទី១ អធិការដ្ឋាននៃ

---

[1] យ៉ង់ ធី និង ស៊ន សំណាង ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សា នៅកម្ពុជា ឆ្នាំ១៩៩៩

ការសិក្សាសាលាវត្តមានលោក **អ៊ុំ ឈាងស៊ុន** ជាអធិការ នាយក និងក្រុមទី២ អធិការដ្ឋាននៃការសិក្សាបារាំង-ខ្មែរ មានលោក **ចែត្រ ឆែម** ជាអធិការនាយក[2]។ នៅឆ្នាំ ១៩៥៩ ក្រុមទាំងពីរនេះរួមបញ្ចូលគ្នាបង្កើតជាអធិការដ្ឋានបឋមសិក្សាដែលមានលោកអធិការនាយកម្នាក់ និងអធិការរងពីរនាក់ជាជំនួយការទទួលបន្ទុកៈ

– អធិការកិច្ចសាលាវត្ត និងអធិការកិច្ចសាលាសាធារណៈ

– ត្រួតពិនិត្យសាលាឯកជន។

នៅគ្រប់ខេត្តមានបង្កើតតំបន់អធិការកិច្ចសាលារៀន ហើយតំបន់អធិការកិច្ចនីមួយៗ មានគ្រូក្រោមឱវាទជាង ១០០ នាក់។ ក្នុងនោះអធិការបឋមសិក្សាមានតួនាទីសំខាន់បីគឺៈ (១)តំណាងអាជ្ញាធរមានសមត្ថកិច្ចតំណាងឱ្យក្រសួង (បឋម មធ្យម ការិយាល័យ) (២)ជាអ្នកបច្ចេកទេសបឋមសិក្សាពិនិត្យលើគ្រប់មុខវិជ្ជាភាសា វិទ្យាសាស្ត្រសង្គម គណិតវិទ្យា។ អធិការជ្រើសរើសក្នុងចំណោមគ្រូបឋមសិក្សា ឬ គ្រូមធ្យមសិក្សាបឋមភូមិ ក្រៅពីនេះគ្រូមធ្យមសិក្សាបឋមភូមិជាអ្នកបច្ចេកទេស ទៅមើលការបង្រៀន គ្រូកម្មសិក្សាមុននឹងតែងតាំងស៊ប់ (៣)គ្រូឧទ្ទេស ពេលជួបបញ្ហានីមួយៗមានការប្រជុំគរុកោសល្យគ្រង់ៗ និងជាសម្ងាត់។ ភាគច្រើននៃការធ្វើអធិការកិច្ច គឺឱ្យដំបូន្មានទៅលើការបង្រៀនភាសាបារាំង ដំបូន្មានគរុកោសល្យ និយ័តភាព និងការមកបង្រៀនមិនបានទៀងទាត់។ ចំពោះ អធិការមធ្យមសិក្សាគឺជាអធិការឯកទេស ដែលក្នុងនោះអធិការគណិតវិទ្យាទៅមើលគណិតវិទ្យា អធិការអក្សរសាស្ត្រខ្មែរទៅមើលអក្សរសាស្ត្រខ្មែរ ប៉ុន្តែពុំសូវបានទៅមើលទេ ដូចជាលោក **កែវ ចែម អ៊ឹម រុន** ទៅមើលតាមមុខវិជ្ជា។

នៅឆ្នាំ ១៩៦៩-១៩៧០ ទូទាំងប្រទេសមាន ១៩៨ តំបន់អធិការកិច្ច។ រចនាសម្ព័ន្ធនៃការសិក្សាអប់រំចំណេះទូទៅនៅសម័យសង្គមរាស្ត្រនិយមមានរយៈពេល ១៣ឆ្នាំ ដែលក្នុងនោះបឋមសិក្សា មាន ៦ កម្រិតថ្នាក់(ពីថ្នាក់ទី ១២ ដល់ថ្នាក់ទី ៧) អនុវិទ្យាល័យមាន ៤ កម្រិតថ្នាក់(ពីថ្នាក់ទី ៦ ដល់ថ្នាក់ទី ៣) និងវិទ្យាល័យមាន ៣ កម្រិតថ្នាក់(គឺថ្នាក់ទី២ ទី១ និងទីបញ្ចប់) ។

## ១.៣-ការសិក្សាអប់រំពីឆ្នាំ ១៩៧៩ ដល់បច្ចុប្បន្ន

– ដំណាក់កាលទី១ ៖ ពីឆ្នាំ ១៩៧៩-១៩៨៧ ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល ១០ ឆ្នាំ ដែលក្នុងនោះសាលាកម្រិតសិក្សាទី១ មាន៤កម្រិតថ្នាក់ (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៤) សាលាកម្រិតសិក្សាទី២ មាន ៣ កម្រិតថ្នាក់ (ពីថ្នាក់ទី ៥ ដល់ថ្នាក់ទី៧) និងសាលាកម្រិតសិក្សាទី ៣ មាន ៣ កម្រិតថ្នាក់(ពីថ្នាក់ទី៨ ដល់ថ្នាក់ទី១០)។

– ដំណាក់កាលទី២ ៖ ពីឆ្នាំ ១៩៨៧-១៩៩៤ ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល ១១ ឆ្នាំ ដែលក្នុងនោះ បឋមសិក្សាមាន ៥ កម្រិតថ្នាក់(ពីថ្នាក់ទី១ ដល់ថ្នាក់ទី៥) មធ្យមសិក្សាកម្រិត១ មាន ៣ កម្រិតថ្នាក់(ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៨) និងមធ្យមសិក្សាកម្រិត២មាន៣ កម្រិតថ្នាក់(ពីថ្នាក់ទី៩ ដល់ ថ្នាក់ទី១១)។

– ដំណាក់កាលទី៣ ៖ ពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល ១២ ឆ្នាំ ដែលក្នុងនោះការអប់រំបឋមសិក្សាចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល

[2] យ៉ង់ ធី និង ស៊ន សំណាង ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សា នៅកម្ពុជា ឆ្នាំ១៩៩៩

ដំណាក់កាលទី១ មធ្យមសិក្សាបឋមភូមិចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និងដំណាក់កាលទី២ មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។

ដើម្បីរួមចំណែកដល់ការពង្រឹងគុណភាពអប់រំ នៅឆ្នាំ ១៩៩៤ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតក្របខណ្ឌអធិការ ក្នុងការត្រួតពិនិត្យនិងតាមដានលើការដឹកនាំ និងគ្រប់គ្រង និងការបង្រៀន និងរៀននៅតាមរាជធានី ខេត្ត។ ក្នុងនោះក្រសួងបានបណ្តុះបណ្តាល អធិការបឋមសិក្សា ៦ ជំនាន់ចំនួន ២៣០ នាក់ អធិការមធ្យមសិក្សា ៤ ជំនាន់ ចំនួន ៧៣ នាក់។

***អធិការបឋមសិក្សាមានភារកិច្ចសំខាន់ៗ ៤ គឺ៖**

១-ណែនាំការអនុវត្តគោលនយោបាយអប់រំ ការណែនាំផ្សេងៗ កម្មវិធីសិក្សានិងសៀវភៅសិក្សា។

២-ជួយបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនតាមការចាំបាច់ នៅតាមរាជធានី ខេត្ត។

៣-ធ្វើអធិការកិច្ច វាយតម្លៃគ្រូបង្រៀន និងនាយកសាលារៀន ព្រមទាំងផ្តល់យោបល់ក្នុងរបាយការណ៍អធិការកិច្ចទៅលើបញ្ហាផ្សេងៗពាក់ព័ន្ធដល់ការងារបុគ្គលិក។

៤-ធ្វើទំនាក់ទំនងជាមួយសហគមន៍ អាជ្ញាធរ អង្គភាព ស្ថាប័ន និងមជ្ឈដ្ឋាននានា ដើម្បីបុព្វហេតុលើកកម្ពស់គុណភាពអប់រំ។

***អធិការមធ្យមសិក្សាមានភារកិច្ចសំខាន់ៗ ៥ គឺ៖**

១-ណែនាំការអនុវត្តគោលនយោបាយអប់រំ ការណែនាំផ្សេងៗកម្មវិធីសិក្សា និងសៀវភៅសិក្សា។

២-វាយតម្លៃ និងផ្តួចផ្តើមគំនិតកែលម្អអំពីសកម្មភាពបង្រៀន និងរៀនក្នុងក្របខណ្ឌមុខវិជ្ជាឯកទេសរបស់ខ្លួន។

៣-ធ្វើអធិការកិច្ច វាយតម្លៃគ្រូបង្រៀនក្នុងក្របខណ្ឌនៃមុខវិជ្ជារបស់ខ្លួន។

៤-ជួយការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនតាមការចាំបាច់នៅតាមរាជធានី ខេត្ត។

៥-ផ្តល់យោបល់ក្នុងរបាយការណ៍អធិការកិច្ចទៅលើបញ្ហាផ្សេងៗពាក់ព័ន្ធដល់ការងារបុគ្គលិក។

- អធិការបឋមសិក្សាត្រូវបានចាត់តាំងឱ្យបម្រើការនៅការិយាល័យអធិការកិច្ច នៃនាយកដ្ឋានបឋមសិក្សានិងមត្តេយ្យសិក្សាក្រោមការដឹកនាំផ្ទាល់របស់ប្រធាននាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា។ ចំណែកអធិការនៅតាមរាជធានី ខេត្ត ត្រូវបានប្រមូលផ្តុំនៅការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំយុវជន និងកីឡាក្រោមការដឹកនាំផ្ទាល់របស់ប្រធានមន្ទីរ។
- អធិការមធ្យមសិក្សាត្រូវបានចាត់តាំងឱ្យបម្រើការនៅការិយាល័យអធិការកិច្ច នៃនាយកដ្ឋានមធ្យមសិក្សាក្រោមការដឹកនាំផ្ទាល់របស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។ ចំណែកអធិការនៅតាមរាជធានី ខេត្ត ត្រូវបានប្រមូលផ្តុំនៅការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំយុវជន និងកីឡាក្រោមការដឹកនាំផ្ទាល់របស់ប្រធានមន្ទីរ។

ដើម្បីរួមចំណែកដល់ការលើកកម្ពស់គុណភាពអប់រំ អធិការមួយចំនួនត្រូវបានលើកទឹកចិត្តដំឡើងតួនាទី។ ទន្ទឹមនឹងនេះ ដើម្បីជំរុញដល់ការធានាគុណភាពដែលអាចទទួលយកបានក្នុងការងារអប់រំ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវចាប់យកការិយាល័យអធិការកិច្ច និងការិយាល័យផែនការជាការិយាល័យស្នូលរបស់ខ្លួន ហើយកិច្ចការបន្ទាប់ គឺការងារបុគ្គលិក និងហិរញ្ញវត្ថុ។

## ២-សេចក្តីផ្តើម

ការរីកចម្រើនយ៉ាងឆាប់រហ័សឥតឈប់ឈរ និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីយកម្ម ទាមទារឲ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឲ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធានមនុស្សឲ្យអស់លទ្ធភាពមានសារៈសំខាន់បំផុតពីព្រោះ វាជាកម្លាំងចលករមិនអាចខ្វះបាន។ ការធានាគុណភាពអប់រំ ដោយការធ្វើអធិការកិច្ច ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ និងកម្មវិធីវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិ ត្រូវបានគេទទួលស្គាល់ និងឲ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។

សមាហរណកម្មនៅក្នុងតំបន់តម្រូវឲ្យកម្ពុជាចូលរួមក្នុងកិច្ចសហការ និងប្រកួតប្រជែងជាមួយប្រទេស ជិតខាងលើគ្រប់វិស័យ ដើម្បីសម្រេចបានចក្ខុវិស័យរួមរបស់អាស៊ាន។ ដើម្បីអាចសម្របខ្លួនទៅនឹងការវិវត្តរបស់ពិភពលោក និងតំបន់ក្នុងន័យបង្កើនភាពឆ្លើយតប និងការប្រកួតប្រជែង កម្ពុជាត្រូវតែមានធនធានមនុស្សដែលមានសមត្ថភាព និងវិជ្ជាជីវៈខ្ពស់។ ការសិក្សាក្នុងតំបន់ដោយប្រព័ន្ធវាយតម្លៃ និងវាស់វែងលទ្ធផលអប់រំបានកំណត់គោលដៅក្នុងការអភិវឌ្ឍគោលនយោបាយធានាគុណភាពអប់រំ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ដូចមានចែងក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។

ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស តាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ដែលស្ថិតក្នុងមុំទី៤ ហើយដោយយកអភិបាលកិច្ចល្អជាស្នូល។ ច្បាប់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់គុណភាពអប់រំ យន្តការវាយតម្លៃគុណភាពអប់រំ កំណត់សិទ្ធិ និងកាតព្វរបស់បុគ្គលិកអប់រំ សិទ្ធិទទួលបានការអប់រំ សិទ្ធិចុះឈ្មោះចូលសិក្សា សិទ្ធិស្មើ សិទ្ធិតវ៉ា សិទ្ធិប្តឹង និងសិទ្ធិទទួលបានដំណោះស្រាយ[3]។

ក្រសួងអប់រំ យុវជន និងកីឡាជាក្រសួងអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដែលមានចំនួនបុគ្គលិកបម្រើការងារច្រើនជាងគេ។ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡាមានសារៈសំខាន់ណាស់ ព្រោះមិនត្រឹមតែជួយធ្វើសនិទានកម្មធនធានមនុស្សក្នុងវិស័យប៉ុណ្ណោះទេ គឺថែមទាំងរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការធ្វើឲ្យគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលអាចអនុវត្តបានដោយល្អប្រសើរ និងមានចីរភាព ពិសេសការប្រើប្រាស់ធនធានមនុស្សក្នុងមុខងារសាធារណៈ។ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលបានដាក់ចេញនូវគោលនយោបាយចំនួន៣គឺ (១)ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២)លើកកម្ពស់គុណភាព និងភាពឆ្លើយតប និង(៣)ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រខាងលើ ក្រសួងបានដាក់ចេញវិធានការអាទិភាពនៃកំណែ

[3] ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា១៧

ទម្រង់វិស័យអប់រំ យុវជន និងកីឡាចំនួន៨ចំណុចដែលមានដូចជា ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ការពង្រឹងការគ្រប់គ្រងបុគ្គលិក ការពង្រឹងការប្រឡងគ្រប់ប្រភេទ ការកែទម្រង់ឧត្តមសិក្សា ការអភិវឌ្ឍសម្រាប់យុវជន នូវជំនាញបច្ចេកទេស និងជំនាញទន់ ការអនុវត្តស៊ីជម្រៅកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ការងារអប់រំកាយ និងកីឡា និងការបង្កើតធនាគារខួរក្បាលវិស័យអប់រំ ដែលក្នុងនោះ ការងារអធិការកិច្ចស្ថិតនៅក្នុងវិធានការទី១។

ការកសាងបញ្ញត្តិនៃការធានាគុណភាពអប់រំ កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា មានវិសាលភាពលើការងារអធិការកិច្ចអប់រំសាធារណៈ និងឯកជនចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការលើកកម្ពស់គុណភាពអប់រំ សំដៅបង្កើនគុណភាព ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ ជំនឿទុកចិត្ត និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនៃការដឹកនាំនិងគ្រប់គ្រង ការរៀន និងបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។

គុណភាពប្រព័ន្ធអប់រំសាធារណៈ គឺជាបញ្ហាដែលអ្នកពាក់ព័ន្ធជាច្រើនកំពុងយកចិត្តទុកដាក់ ដោយផ្អែកលើមូលហេតុចម្បងពីរគឺ កត្តាសមធម៌ និងកត្តារីកចម្រើនផ្អែកគោលនយោបាយ។ កត្តាសមធម៌ គឺសំដៅលើការផ្តល់ឱកាសស្មើៗគ្នាដល់ជនគ្រប់រូប ដើម្បីទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់ ហើយគប្បី អនុវត្តនៅទូទាំងប្រទេស[4]។ កត្តារីកចម្រើនផ្អែកគោលនយោបាយ គឺសំដៅធ្វើឲ្យប្រជាជនដែលមានការអប់រំខ្ពស់ជាអ្នករៀបចំគាំពារសុខមាលភាពជារួមរបស់យើង។

ច្បាប់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឲ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ[5]។

ការអប់រំមានគុណភាពល្អ គឺជាកត្តាដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេស។ បន្ទាប់ពីទទួលបានសន្តិភាពក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាទទួលបានសន្តិភាព និងសម្រេចបានសមិទ្ធផលជាច្រើនក្នុងចន្លោះរយៈពេល២០ឆ្នាំនេះ ជាពិសេសគឺការផ្តោតការយកចិត្តទុកដាក់ និងការតាំងចិត្តក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំរបស់ប្រទេស។ ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ បានបង្ហាញអំពីការប្រែប្រួលជាច្រើន ហើយនេះក៏ជាសញ្ញាបង្ហាញថាក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការកែទម្រង់វិស័យអប់រំ យុវជន និងកីឡារបស់ប្រទេសជាបន្តទៀត ស្របជាមួយនឹងកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល។ ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៥ឆ្នាំកន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍរបស់ខ្លួនបានធ្វើការកែលម្អដ៏សំខាន់ក្នុងការផ្តល់ឱកាសចូលរៀនប្រកបដោយសមធម៌ ការកែលម្អគុណភាព និងប្រសិទ្ធភាពអប់រំ និងការគ្រប់គ្រងអប់រំ។ ប្រទេសកម្ពុជាមានសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិប្រហែល ៨ ៣០០ សាលារៀនមធ្យមសិក្សាទុតិយភូមិជិត៤៥៥ ក្នុងនោះប្រមាណ ៤ ភាគរយជាសាលារៀនឯកជន រីឯសាលាមត្តេយ្យសិក្សាវិញមានចំនួន

---

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៦៦ និង ៦៨

[5] ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា២ មាត្រា៣១ និង៣២

ប្រហែល ៣ ០០០។ សិស្សគ្រប់កម្រិតសិក្សាទាំងអស់មានចំនួនប្រហែល ៣.១លាន នាក់កំពុងសិក្សាក្នុងសាលារៀន[6]។

កុមារគ្រប់រូប មានសិទ្ធិចូលរៀនក្នុងសាលារៀនចំណេះទូទៅនៅអាយុ៦ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ខែឡើងទៅនៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន។ ជនគ្រប់រូបមានសិទ្ធិទទួលការអប់រំនៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងបន្តទៅមធ្យមសិក្សាទុតិយភូមិ[7]។

រូបខាងក្រោមបង្ហាញអំពីការរៀបចំប្រព័ន្ធអប់រំរបស់កម្ពុជា[8]។




ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវបានរៀបចំឡើងដើម្បីធានាទំនាក់ទំនងរវាងគោលនយោបាយអប់រំ និងយុទ្ធសាស្ត្រនានាទៅនឹងកម្មវិធី និងសកម្មភាពអភិវឌ្ឍន៍ក៏ដូចជាផែនការ និងការគ្រោងថវិកាជាដើម។ ក្នុងដំណាក់កាលនេះ ក្រសួងមានគោលបំណងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការចូលរៀនប្រកបដោយសមធម៌ និងគុណភាពអប់រំខ្ពស់ ពិសេសនៅកម្រិតអប់រំមូលដ្ឋានក្នុងគោលបំណងឆ្លើយតបទៅនឹងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ ក៏បានផ្តោតជាសំខាន់ ផងដែរលើការពង្រីកការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការពង្រីកឱកាសចូលរៀននៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា[9]។

---

[6] ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ២០១២-២០១៣

[7] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៦៨

[8] ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា១៧ និងមាត្រា ១៨

[9] ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០០១៣

ការធានាឲ្យការអប់រំមានគុណភាពល្អ មានស្តង់ដារ និងខ្លឹមសារខ្ពស់ ការទទួលដឹងអំពីគុណភាព និងការកំណត់ថាគុណភាពមានន័យយ៉ាងដូចម្តេចនោះ គឺជារឿងសំខាន់ណាស់។ នេះតម្រូវឲ្យមានការចូលរួមពីគ្រប់កម្រិតទាំងអស់ចាប់តាំងពីស្ថាប័នសភាជាតិ ក្រសួងអប់រំ យុវជន និងកីឡា សាលារៀន នាយកសាលា និងគ្រូបង្រៀន ហើយក៏ត្រូវទទួលស្គាល់ពីសំណាក់មាតាបិតា សិស្សានុសិស្ស និងសង្គមទាំងមូលផងដែរ។

ច្បាប់ស្តីពីការអប់រំបានកំណត់ថា រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្តីត្រូវការខាងការសិក្សាជាមូលដ្ឋាន និងសេចក្តីត្រូវការជំនាញ សម្រាប់ធ្វើឲ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព[10]។

បន្ថែមលើនេះ កិច្ចខិតខំប្រឹងប្រែងក៏បានផ្តោតផងដែរ ដើម្បីធានាឲ្យការចំណាយលើការងារអប់រំប្រកបដោយប្រសិទ្ធភាព ដោយបានដាក់ចេញជាមធ្យោបាយនានា ដូចជាការផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ការជួយកុមារ និងយុវជនដែលបាត់បង់ឱកាសទទួលការអប់រំជាដើម។ ចំណុចសំខាន់ដទៃទៀតមានដូចជា ការពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងអភិបាលកិច្ចល្អ។ ទាំងនេះគឺជាសមាសភាពនៃសកម្មភាពដើម្បីសម្រេចបានគុណភាពល្អ។ *ការធានាគុណភាពអប់រំ* គឺជាការងារអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា[11]។

ឯកសារនេះបានផ្តោតជាចម្បងលើសមាសភាគ *អធិការកិច្ច* ប៉ុន្តែសមាសភាគពីរផ្សេងទៀតដែលមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយការងារអធិការកិច្ច គឺស្វ័យវាយតម្លៃ ការផ្តល់យោបល់ និងណែនាំ ក៏ត្រូវបានលើកមកពិភាក្សាផងដែរក្នុងឯកសារនេះ។

ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចកែប្រែទស្សនវិស័យលើការងារអធិការកិច្ច ពីការធ្វើអធិការកិច្ចលើមុខវិជ្ជា និងគ្រូបង្រៀន ទៅជាការធ្វើអធិការកិច្ចសាលារៀនជាប្រព័ន្ធវិញ[12]។ អត្ថបទខាងក្រោមនឹងមានបង្ហាញអំពីភាពខុសគ្នារវាងការធ្វើអធិការកិច្ចទាំងពីររបៀបនេះ។

## ៣-ក្របខណ្ឌធានាគុណភាព

ការធានាគុណភាព គឺសំដៅលើសកម្មភាពទាំងឡាយដែលបានគ្រោង និងមានលក្ខណៈជាប្រព័ន្ធ ហើយត្រូវបានអនុវត្តក្នុងប្រព័ន្ធមួយ ឬ អង្គភាពមួយ ដើម្បីធ្វើឲ្យតម្រូវការផ្នែកគុណភាពត្រូវបានបំពេញ ហើយអង្គភាពនោះត្រូវផ្តល់នូវផលិតផលដែលល្អបំផុត។

សកម្មភាពធានាគុណភាព នឹងផ្តោតលើការពង្រឹង និងកែលម្អដំណើរការដែលត្រូវប្រើប្រាស់ដើម្បីបង្កើតលទ្ធផលចុងក្រោយ។ ចំពោះប្រព័ន្ធអប់រំកម្ពុជា សកម្មភាពធានាគុណភាពមានន័យថា ធ្វើឲ្យកុមារ ឬ សិស្សទាំងអស់ទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឲ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ[13]។

---

[10]ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា២១

[11]ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣

[12]អនុស្សរណៈនៃការយោគយល់រវាងក្រសួងអប់រំ យុវជន និងកីឡា និងអធិការដ្ឋានអប់រំ ប្រទេសស៊ុយអែត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២

[13] កិច្ចប្រជុំគណៈកម្មការដឹកនាំកម្មវិធី ភ្នំពេញ ខែធ្នូ ឆ្នាំ២០១២

ការធានាគុណភាពមានសភាពស្មុគ្រស្មាញណាស់។ ក្របខណ្ឌធានាគុណភាព រួមផ្សំដោយសមាសភាគ និងសកម្មភាពមួយចំនួនដែលត្រូវផ្សារភ្ជាប់គ្នាតាំងពីថ្នាក់ក្រោម រហូតដល់ថ្នាក់លើបំផុត។




ការធានាគុណភាពមានន័យថា ត្រូវធ្វើការជាមួយគ្រប់សមាសភាគទាំងអស់។ វត្ថុបំណងជាមូលដ្ឋានរបស់គោលការណ៍ណែនាំនេះ គឺសម្រាប់បង្ហាញផ្លូវដល់អ្នកអនុវត្ត នាយកសាលារៀន និងគ្រូបង្រៀនដែលជាអ្នកដឹកនាំ និងអនុវត្តភារកិច្ចនេះ។

| | | |
|---|---|---|
| **ស្វ័យវាយតម្លៃសាលារៀន**<br>កម្រិតសាលារៀន | **អធិការកិច្ច** | **ការផ្តល់យោបល់ និងណែនាំ** |
| **ការទិតៀន**<br>គ្រប់គ្រង | **លទ្ធផល**<br>តាមដានសមិទ្ធផល | **ការបណ្តុះបណ្តាលគ្រូ**<br>**ការបំប៉នគ្រូ** |
| **ការដឹកនាំ**<br>ការបណ្តុះបណ្តាលនិងគាំទ្រ | **ការធ្វើតេស្ត**<br>តេស្តថ្នាក់ជាតិ, PISA, TIMMS | **ការវិភាគ** |
| **លក្ខខណ្ឌ** | | **ព័ត៌មាន** |
| **វត្ថុបំណង - គោលការណ៍ណែនាំ** | | |

ទោះបីយើងធ្វើការលើសមាសភាគធានាគុណភាពផ្សេងៗគ្នាក៏ដោយ ក៏ខ្សែចង្វាក់សកម្មភាពនៅតែដដែល។ ឧទាហរណ៍ ប្រសិនបើយើងផ្តោតលើគោលការណ៍ណែនាំ យើងត្រូវធ្វើការពិនិត្យតាមដានលើផលប៉ះពាល់ពីការអនុវត្តរួចធ្វើការវិភាគរកមើល ថាតើគោលការណ៍នោះសមស្របទៅនឹងវត្ថុបំណងជារួមហើយឬនៅ។ មានន័យថា យើងត្រូវតែធ្វើការវិភាគ ធ្វើការសម្រេចចិត្ត និងធ្វើការកែប្រែ។

សកម្មភាពសំខាន់ៗក្នុងដំណើរការធានាគុណភាពមាន ៖

– ការពិនិត្យតាមដាន និងការត្រួតពិនិត្យ ជារឿយៗសកម្មភាពនេះ ត្រូវផ្អែកលើលទ្ធផលជាស្ថិតិ។

សកម្មភាពនេះត្រូវបានអនុវត្ត ដើម្បីពិនិត្យមើលឲ្យបានស៊ីជម្រៅទៅលើដំណើរការជាប្រព័ន្ធ ដែលបានគ្រោងដើម្បីបំពេញតម្រូវការ

– **ការវិភាគ** ប្រើប្រាស់ទិន្នន័យដែលប្រមូលបានទាំងអស់ ដើម្បីធ្វើការសន្និដ្ឋានលើដំណើរការពិនិត្យតាមដាន និងការត្រួតពិនិត្យ

– **សេចក្តីសន្និដ្ឋាន** ធ្វើការសម្រេចចិត្តថាចំណុចណាខ្លះដែលមិនទាន់បានល្អ ហើយត្រូវបង្កើតវិធានការណ៍ដើម្បីកែលម្អ

– **ការផ្តល់ព័ត៌មានត្រឡប់** អនុវត្តសកម្មភាពដើម្បីកែប្រែឥរិយាបថ និងកែលម្អលទ្ធផល

– **វិធានការថ្មី**

សកម្មភាពទាំងនេះមានតួនាទីសំខាន់ៗបី ៖

– **ការអនុវត្ត** ផ្តល់គណនេយ្យភាព ដោយផ្អែកលើការវាយតម្លៃ

– **ការផ្តល់ព័ត៌មាន**

➢ ផ្តល់លទ្ធផលជូនរាជរដ្ឋាភិបាលដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ទូទាំងប្រទេស

➢ ផ្តល់ព័ត៌មានត្រឡប់ទៅសាលារៀន និងសាធារណៈជនដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ទូទាំងប្រទេស

– **ការផ្តល់មូលដ្ឋានសម្រាប់វាយតម្លៃដំណើរការ និងកំណត់ផ្នែកដែលត្រូវធ្វើការកែលម្អ។**

ក្រៅពីការវាស់វែងប្រព័ន្ធទៅតាមស្តង់ដារ *ការពិនិត្យតាមដាន* និង*ត្រួតពិនិត្យ* ត្រូវតែផ្សារភ្ជាប់ទៅនឹងដំណើរការផ្តល់ព័ត៌មានត្រឡប់ដើម្បីបង្ការកំហុស និងលទ្ធផលមិនល្អ។ ដំណើរការផ្តល់ព័ត៌មានត្រឡប់ក៏ត្រូវរួមបញ្ចូលផងដែរនូវការណែនាំសាលារៀនដើម្បីឈានទៅសម្រេចវត្ថុបំណងរបស់ខ្លួន។

ពាក្យ *អធិការកិច្ច* ជារឿយៗគឺសំដៅលើការត្រួតពិនិត្យ ដែលជាពាក្យមានន័យអវិជ្ជមាន ប៉ុន្តែអធិការកិច្ចក៏ជាឧបករណ៍មួយសម្រាប់អនុវត្ត និងកែលម្អផងដែរ។ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃបានផ្តល់ព័ត៌មានដ៏សំខាន់ដែលអាចប្រើប្រាស់សម្រាប់ណែនាំ និងផ្តល់យោបល់ផងដែរ។

ប្រព័ន្ធធានាគុណភាពអប់រំដែលមានដំណើរការល្អនៅកម្រិតមូលដ្ឋាន គឺជាការធានាសកម្មភាពជាបន្តបន្ទាប់សម្រាប់ឲ្យមានការកែលម្អ ហើយស្វ័យវាយតម្លៃ បានដើរតួយ៉ាងសំខាន់ក្នុងប្រព័ន្ធធានាគុណភាពនេះ។ ដូចនេះ **ការងារអធិការកិច្ច ត្រូវតែចូលរួមផ្តល់វិភាគទានដល់ការអភិវឌ្ឍន៍ និងអនុវត្តជាប្រចាំ ដើម្បីឲ្យប្រព័ន្ធស្វ័យវាយតម្លៃមានប្រសិទ្ធភាពនៅគ្រប់សាលារៀនទាំងអស់**[14]។

## ៤-ឧបករណ៍អធិការកិច្ចសម្រាប់ការធានាគុណភាព

### ៤.១-គោលបំណងអធិការកិច្ច

ច្បាប់ស្តីពីការអប់រំ ត្រង់មាត្រា៩ បានកំណត់អំពីប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ មានភារកិច្ចទទួលខុសត្រូវរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ។

ការធ្វើអធិការកិច្ចសាលារៀន គឺជាយន្តការត្រួតពិនិត្យ និងតាមដានថាតើសាលារៀនបានសម្រេចតម្រូវការរបស់ខ្លួនត្រឹមកម្រិតណា។ អធិការកិច្ចក៏អាចវាយតម្លៃផងដែរថាតើសាលារៀនអាចសម្រេចបានទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងច្បាប់ស្តីពីការអប់រំបានត្រឹម

[14]កិច្ចប្រជុំគណៈកម្មការដឹកនាំកម្មវិធី នៅទីក្រុងស្តុកហូម ប្រទេសស៊ុយអែត ថ្ងៃទី២៤ ខែឧសភា ២០១៣

កម្រិតណា។ អធិការត្រូវធ្វើការវាយតម្លៃថា តើសកម្មភាពអប់រំដែលសាលារៀនកំពុងធ្វើទាក់ទងនឹងវត្ថុបំណង និងកម្មវិធីសិក្សារបស់ជាតិសម្រេចបានល្អត្រឹមកម្រិតណាហើយ។ អាចនិយាយបានថា *ភារកិច្ចសំខាន់បំផុតរបស់អធិការគឺពិនិត្យមើលថាតើសាលារៀនមានប្រព័ន្ធសម្រាប់ធ្វើស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រស្វ័យកែលម្អហើយឬនៅ*។ បន្ថែមលើការពិនិត្យនេះ អធិការក៏ត្រូវតែចូលរួមក្នុងការអនុវត្តទាំងនោះផងដែរ។

**ជាសង្ខេបគោលបំណងរួមរបស់អធិការកិច្ច គឺកែលម្អអ្នកសិក្សាទាំងអស់ តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងពង្រឹងសមត្ថភាពធ្វើស្វ័យវាយតម្លៃ។ អធិការកិច្ចក៏ត្រូវវាយតម្លៃសាលារៀនផងដែរដើម្បីបង្ហាញអំពីចំណេះដឹង និងស្ថានភាពសិក្សាជាក់ស្តែងរបស់ប្រទេស។**




### ៤.២-តួនាទីអធិការ

អធិការមានតួនាទីជាមន្ត្រីគ្រប់គ្រងអប់រំ និងជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវបានតែងតាំងឱ្យបំពេញភារកិច្ចនៅថ្នាក់ក្រសួង (នាយកដ្ឋានធានាគុណភាពអប់រំ) និងការិយាល័យអធិការកិច្ច នៅថ្នាក់រាជធានី ខេត្តតាមការចាំបាច់ និងតាមតម្រូវការ។ ក្នុងតួនាទីនេះ អធិការត្រូវមានមនសិការ និងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង និងចំពោះមុខរាជធានី ខេត្ត ដោយខិតខំធ្វើឱ្យឃើញច្បាស់ពីការរួមចំណែករបស់ខ្លួនក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈការងារអធិការកិច្ច។ ទន្ទឹមនឹងតួនាទីនេះ អធិការត្រូវដើរតួសំខាន់៤ ដូចខាងក្រោម៖

១-តំណាងអាជ្ញាធរមានសមត្ថកិច្ច តំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា។

២-ជាអ្នកបច្ចេកទេសត្រួតពិនិត្យលើគ្រប់មុខវិជ្ជាទាំងផ្នែកភាសា ផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។

៣-ជាគ្រូឧទ្ទេសពេលជួបបញ្ហានីមួយៗមានការប្រជុំគរុកោសល្យត្រង់ៗ និងជាសម្ងាត់។

៤-ធ្វើអធិការកិច្ចលើប្រព័ន្ធសាលារៀនទាំងមូល[15]។

ក្រៅពីតួនាទីខាងលើ អធិការនៅមានភារកិច្ច ៥ជាមូលដ្ឋានទៀតគឺ: (១)ជាអ្នកណែនាំ អនុវត្តគោលនយោបាយអប់រំ (២)ជាអ្នកវាយតម្លៃ (៣)ជាអ្នកធ្វើអធិការកិច្ច (៤)ជាទីប្រឹក្សាគរុកោសល្យ និង (៥)ជាអ្នកផ្តល់ការវិនិច្ឆ័យផ្សេងៗតាមផ្លូវច្បាប់។

---

[15] ក្រសួងអប់រំ យុវជន និងកីឡា អធិការកិច្ច ដើម្បីធានាគុណភាពអប់រំនៅមធ្យមសិក្សាចំណេះទូទៅ ឆ្នាំសិក្សា ១៩៩៩ - ២០០០

### ៤.៣-វិធីសាស្ត្រធ្វើអធិការកិច្ច

អធិការកិច្ចអាចអនុវត្តបានតាមវិធីផ្សេងៗគ្នា។ ឯកសារនេះ នឹងលើកយកតែ**អធិការកិច្ចផ្ទៃក្នុង** និង **អធិការកិច្ចផ្ទៃក្រៅ** តែប៉ុណ្ណោះមកពិពណ៌នា។

**អធិការកិច្ចផ្ទៃក្នុង** គឺផ្អែកលើការធ្វើស្វ័យវាយតម្លៃរបស់សាលារៀន ដែលអនុវត្តដោយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស។ កិច្ចការនេះក៏ត្រូវផ្តោតផងដែរលើការងារទាក់ទងនឹងគុណភាពផ្ទៃក្នុងនៅកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានផ្ទៃក្នុង ឬ ធនធានមូលដ្ឋាន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំ ប៉ុន្តែពុំសូវមានលក្ខណៈផ្លូវការដូចអធិការកិច្ចពីខាងក្រៅទេ ហើយចំពោះការធ្វើការកែលម្អអ្វីមួយវិញក៏ត្រូវធ្វើឡើងជាប្រចាំផងដែរក្នុងអំឡុងឆ្នាំសិក្សា។

**អធិការកិច្ចផ្ទៃក្រៅ** គឺជាការធ្វើអធិការកិច្ចរយៈពេលខ្លីណាមួយដោយអ្នកដែលមកពីខាងក្រៅសាលារៀន។ ការធ្វើអធិការកិច្ចនេះគឺជាការសាកសួរដើម្បីរកឲ្យឃើញនូវផ្នែកទាំងឡាយណា ដែលសាលារៀនបំពេញបានល្អ ឬមិនទាន់បានល្អ រួចរិះរកវិធានការណ៍ ឬផ្តល់អនុសាសន៍ដើម្បីស្វែងរកតម្រូវការនានាសម្រាប់កែលម្អចំណុចមិនទាន់បានល្អទាំងនោះ។

អធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅ អាចអនុវត្តបានតាមពីររបៀប អាស្រ័យលើអ្វីដែលយើងចង់ផ្តោតលើ និងវត្ថុបំណងនៃសកម្មភាព។ យើងអាចផ្តោតលើផ្នែកខ្លះនៃដំណើរការដោយពិនិត្យលើទិដ្ឋភាពលម្អិត ឬផ្តោតលើប្រព័ន្ធទាំងមូលដោយផ្តោតលើទិដ្ឋភាពគ្រប់ជ្រុងជ្រោយ។ វិធីទាំងពីរនោះគឺ៖

១-ការវាយតម្លៃគ្រូបង្រៀន

២-ការវាយតម្លៃសាលារៀន

***ការវាយតម្លៃគ្រូបង្រៀន*** គឺសំដៅលើការជួយគ្រូបង្រៀនតាមរយៈការសង្កេតថ្នាក់ និងសម្ភាសន៍ផ្ទាល់ជាមួយគ្រូបង្រៀនក្នុងគោលបំណងពិនិត្យមើលលើវិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើ។ ចំណុចដែលត្រូវធ្វើអធិការកិច្ចមានដូចជា ការផ្តោតលើមុខវិជ្ជា មានន័យថាអធិការម្នាក់ពិនិត្យមើលគ្រូបង្រៀនមុខវិជ្ជាគីមីវិទ្យា ហើយអធិការម្នាក់ទៀតពិនិត្យមើលគ្រូបង្រៀនគណិតវិទ្យាជាដើម ការផ្តោតលើឥរិយាបថគ្រូបង្រៀនចំពោះសិស្ស ការផ្តោតលើវិធីសាស្ត្រដែលគ្រូបង្រៀនប្រើដើម្បីបង្ហាញខ្លឹមសារ ការផ្តោតលើវិធីដែលគ្រូបង្រៀនប្រើប្រាស់សៀវភៅសិក្សា និងសម្ភារឧបទេស ការផ្តោតលើសមត្ថភាពរបស់គ្រូបង្រៀនក្នុងការបង្កើតការលើកទឹកចិត្ត គឺជាឧទាហរណ៍នៃសកម្មភាពដែលត្រូវប្រើក្នុងការងារអធិការកិច្ចប្រភេទនេះ។ បន្ទាប់ពីការធ្វើអធិការកិច្ច គ្រូបង្រៀនម្នាក់ៗ នឹងទទួលបាននូវព័ត៌មានត្រឡប់មកវិញទាក់ទងនឹងការបំពេញការងាររបស់ខ្លួនព្រមទាំងអនុសាសន៍សម្រាប់ធ្វើការកែលម្អផងដែរ។

***ការវាយតម្លៃសាលារៀន*** គឺសំដៅលើការការធ្វើអធិការកិច្ចជាប្រព័ន្ធ ពីព្រោះថា អធិការត្រូវពិនិត្យមើលប្រព័ន្ធសាលារៀនក្នុងទិដ្ឋភាពគ្រប់ជ្រុងជ្រោយតែម្តង។ ភារកិច្ចរបស់អធិការ គឺធ្វើឲ្យប្រាកដថាសាលារៀនមានប្រព័ន្ធរបស់ខ្លួនច្បាស់លាស់ និងសមត្ថភាពធ្វើឲ្យសម្រេចតម្រូវការដែលមានចែងក្នុងគោលការណ៍ណែនាំ។ នេះមានន័យថា អធិការមិនត្រូវផ្តោតលើមុខវិជ្ជាជាក់លាក់ណាមួយទេ ប៉ុន្តែអធិការត្រូវផ្តោតជាចម្បងលើគ្រូបង្រៀនទាំងអស់ ព្រមទាំងនាយកសាលាផងដែរ។ ឧទាហរណ៍ អធិការអាចពិនិត្យមើលលើវិធីសាស្ត្រដែលនាយកសាលារៀនដឹកនាំការងារគរុកោសល្យ ការពិនិត្យតាមដានសាលារៀន និង

ស្វ័យវាយតម្លៃសកម្មភាពរបស់គ្រូបង្រៀនទាក់ទងនឹងកម្មវិធីសិក្សា និងកម្រិតយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងបេសកកម្មជាគ្រូបង្រៀន សម្ភារផ្សេងៗរបស់សាលារៀន និងការប្រើប្រាស់សម្ភារទាំងនោះថាតើសមស្របតាមគរុកោសល្យត្រឹមណា។ ការសម្ភាសជាមួយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស និងការធ្វើសង្កេត គឺជាសកម្មភាពចម្បងសម្រាប់អធិការកិច្ចប្រភេទនេះ។ ការផ្តល់ព័ត៌មានត្រឡប់ ត្រូវបានធ្វើចំពោះសាលារៀនទាំងមូលមានន័យថា ត្រូវផ្តល់ជូនអ្នកដែលមានការទទួលខុសត្រូវដើម្បីធានាឲ្យសាលារៀនអនុវត្តតាមគោលការណ៍ណែនាំ។

នៅពេលអនាគត អធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅ គួរផ្តោតលើការធ្វើអធិការកិច្ចប្រភេទទីពីរ គឺការពិនិត្យមើលសាលារៀនក្នុងទិដ្ឋភាពគ្រប់ជ្រុងជ្រោយ[16]។ ប៉ុន្តែនេះមិនមែនមានន័យថា អធិការកិច្ចគ្រូបង្រៀននឹងមិនត្រូវបានយកមកអនុវត្តនោះទេ។ យើងនៅតែមានគំនិតធ្វើអធិការកិច្ចគ្រូបង្រៀន និងវិធីសាស្ត្របង្រៀនរបស់ពួកគាត់តាមរយៈការធ្វើអធិការកិច្ចផ្ទៃក្នុងរបស់នាយកសាលារៀន និងការធ្វើអធិការកិច្ចតាមប្រធានបទ **ពីនាយកដ្ឋានធានាគុណភាពអប់រំ**។

### ៤.៤-ការផ្តល់យោបល់ និងណែនាំ

ក្រោយពេលបញ្ចប់ការធ្វើអធិការកិច្ច អធិការត្រូវផ្តល់អនុសាសន៍ ឬដំបូន្មានទៅដល់អង្គភាព (សាលារៀន) ដែលរងអធិការកិច្ចនូវចំណុចខ្វះខាតមួយចំនួន ដោយផ្អែកលើលទ្ធផលស្វ័យវង្វាយតម្លៃសាលារៀន ផែនការអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ កម្មវិធីសិក្សា ច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ចំពោះបញ្ហាមួយចំនួនដែលសាលារៀនមិនអាចដោះស្រាយបាន (កង្វះគ្រូ អគារសិក្សាទ្រុឌទ្រោម សៀវភៅសិក្សាគោល...) ក្រុមអធិការកិច្ចតាមប្រធានបទ ត្រូវលើកសំណើជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យនិងសម្រេច។

### ៤.៥-ការអភិវឌ្ឍសមត្ថភាពអធិការ

ដើម្បីឲ្យឆ្លើយតបទៅនឹងប្រព័ន្ធអធិការកិច្ចបែបថ្មី នាយកដ្ឋានធានាគុណភាពអប់រំ និងវិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាព តាមរយៈវគ្គបំប៉ន វគ្គបណ្តុះបណ្តាលទាំងអធិការផ្ទៃក្នុង និងអធិការផ្ទៃក្រៅ។ ចំពោះអធិការមានស្រាប់ ត្រូវបំប៉ននូវនិតិវិធីប្រព័ន្ធអធិការកិច្ចបែបថ្មី និងជ្រើសរើសអធិការថ្មីដើម្បីបំពេញតាមតម្រូវការចាំបាច់របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅក្នុងការបំប៉ននាយកសាលា ចាំបាច់ត្រូវឲ្យសាលានីមួយៗចេះកសាងផែនការអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងយល់ដឹងពីឧបករណ៍ស្វ័យវង្វាយតម្លៃសាលារៀន ព្រមទាំងស្វែងយល់ពីប្រព័ន្ធអធិការកិច្ចបែបថ្មី។

## ៥-អធិការកិច្ចផ្ទៃក្នុង




[16] កិច្ចប្រជុំគណៈកម្មការដឹកនាំកម្មវិធី នៅទីក្រុងស្តុកហូម ប្រទេសស៊ុយអែត ថ្ងៃទី២៤ ខែឧសភា ២០១៣

## ៥.១-ស្វ័យវាយតម្លៃសាលារៀន

ប្រព័ន្ធស្វ័យវាយតម្លៃសាលារៀនដ៏មានប្រសិទ្ធភាព និងជាប្រចាំអាចផ្តល់ឱកាសក្នុងការសិក្សាអង្កេតទៅលើជីវភាពខាងក្នុង និងមហិច្ឆិតារបស់សាលារៀន ថាតើបានផ្តល់ផលប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សត្រឹមកម្រិតណាច្រើនជាងអធិការដែលមកមើលសាលារៀនម្តងម្កាល។ ប្រព័ន្ធស្វ័យវាយតម្លៃគឺជាមូលដ្ឋានគ្រឹះសម្រាប់ការងារកែលម្អរយៈពេលវែង។

នាយកសាលារៀនមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំធ្វើស្វ័យវាយតម្លៃសាលារៀន។ ប្រព័ន្ធត្រូវតែអភិវឌ្ឍដោយរួមបញ្ចូលនូវសកម្មភាពចាំបាច់ដូចជា ៖

**១-ការរៀបចំឯកសារ**

**២-ការបន្តពិនិត្យតាមដាន**

**៣-ការវិភាគ និងវាយតម្លៃតម្រូវការអភិវឌ្ឍន៍**

**៤-ការកសាងផែនការ និងការអនុវត្ត។**

ការងារប្រកបដោយគុណភាព និងជាប្រព័ន្ធមានន័យថា សាលារៀនធ្វើការពិនិត្យតាមដានសកម្មភាពជាប្រព័ន្ធ និងជាប្រចាំធ្វើការវិភាគលទ្ធផលដែលទាក់ទងនឹងគោលដៅរបស់ជាតិ និងផ្អែកលើផែនការ និងការអភិវឌ្ឍវិស័យអប់រំ។ បន្ថែមលើលទ្ធផលដែលបានមកតម្រូវឲ្យមានការតាមដាន វិភាគ និងវាយតម្លៃ ដើម្បីបង្ហាញអំពីបទពិសោធន៍ដែលមានលក្ខណៈវិទ្យាសាស្ត្រ និងលេចធ្លោដែលជាការអនុវត្តល្អៗរបស់ពួកគេ។ ជាមួយគ្នានេះ ការកសាងផែនការ និងការកំណត់ផ្នែកអាទិភាពដែលត្រូវធ្វើការអភិវឌ្ឍ ត្រូវយកចិត្តទុកដាក់ជា សំខាន់លើការស្រាវជ្រាវបច្ចុប្បន្ន។

នាយកសាលារៀន ត្រូវវិភាគរកមើលមូលហេតុនៃប្រសិទ្ធភាពខុសៗគ្នារវាងក្រុម និងថ្នាក់ផ្សេងៗគ្នា ឬរវាងមុខវិជ្ជា និងផ្នែកដែលត្រូវផ្តោតនៃកម្មវិធីសិក្សា។ បន្ថែមលើនេះ នាយកសាលារៀន រួមជាមួយនឹងបុគ្គលិកសាលារៀនទាំងអស់ត្រូវរួមគ្នាពិភាក្សា និងវិភាគលើលទ្ធផល និងការពន្យល់ទាំងឡាយដោយផ្អែកលើវត្ថុបំណងថ្នាក់ជាតិជាគោល។

- តើចំណុចសំខាន់នៃបែបបទការងារនិងវិធីសាស្ត្របំពេញការងារអ្វីខ្លះ ដែលធ្វើឲ្យមានប្រសិទ្ធភាព?
- តើត្រូវប្រើប្រាស់ពេលវេលាយ៉ាងដូចម្តេចក្នុងពេលបង្រៀន?
- តើផលប៉ះពាល់អ្វីខ្លះដែលធនធានមនុស្ស (គ្រូបង្រៀន) និងធនធានសម្ភារៈបានផ្តល់ដល់កុមារ និងក្រុមសិស្ស?
- តើសាវតាររបស់គ្រូបង្រៀនជំនាញ គុណតម្លៃ ឥរិយាបថ និងវិធីសាស្ត្រដែលពួកគាត់ប្រើសម្រាប់ អភិវឌ្ឍកុមារ ការសិក្សារបស់សិស្ស និងការផ្តល់ឱកាសដល់សិស្ស បានធ្វើឲ្យសម្រេចវត្ថុបំណងនៃចំណេះដឹងត្រឹមកម្រិតណា?
- តើគ្រូបង្រៀននិងបុគ្គលិកដទៃទៀតមានបំណិនគ្រប់គ្រាន់សម្រាប់បេសកកម្មរបស់គាត់ហើយឬនៅ?

ការងារជាប្រព័ន្ធ និងជានិរន្តមានន័យថា កិច្ចការទាំងនោះត្រូវរៀបចំ និងបន្តដោយផ្តោតលើការអភិវឌ្ឍយូរអង្វែង។ សាលារៀននីមួយៗត្រូវស្វែងរកបែបបទ និងនីតិវិធីរបស់ខ្លួនសម្រាប់ការងារជាប្រព័ន្ធ

ដោយផ្អែកលើស្តង់ដាររបស់ជាតិ។ ចំណុចចាប់ផ្តើមជានិច្ចកាលត្រូវធ្វើដូចៗគ្នា គឺត្រូវកំណត់ផ្នែកដែលត្រូវធ្វើការអភិវឌ្ឍ ដើម្បីសម្រេចឲ្យបានប្រសិទ្ធភាពខ្ពស់បំផុតទាក់ទងនឹងវត្ថុបំណងរបស់ជាតិ។

ដើម្បីអាចធ្វើការតាមដានលើលក្ខខណ្ឌ និងការអនុវត្តការងារអប់រំ ថាទទួលបានប្រសិទ្ធភាពខ្ពស់ប៉ុណ្ណា នោះជាការសំខាន់ គឺត្រូវរៀបចំធ្វើការវិភាគតាមដានកិច្ចការទាំងនោះដោយខ្លួនឯងផ្ទាល់។ ក្នុងពេលអនាគត នាយកសាលារៀននឹងមានលទ្ធភាពប្រើប្រាស់មូលដ្ឋានទិន្នន័យពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (QEMIS) សម្រាប់បម្រើឲ្យសកម្មភាពតាមដានទាំងនោះ។

ការរៀបចំឯកសារ គឺជាការចាំបាច់ដើម្បីចងក្រងជាប្រចាំនូវកិច្ចការគុណភាពដែលនាំទៅដល់ការសម្រេចបានវត្ថុបំណង។ សម្រាប់ទស្សនវិស័យយូរអង្វែង ការរៀបចំឯកសារគឺជាលក្ខខណ្ឌចាំបាច់ដំបូងដើម្បីអាចកំណត់សកម្មភាព និងផ្នែកដែលត្រូវយកចិត្តទុកដាក់ជាសំខាន់សម្រាប់ការអភិវឌ្ឍដើម្បីសម្រេចវត្ថុបំណង។

ភស្តុតាងបានបង្ហាញថា នាយកសាលារៀនដែលក្លាយជាអ្នកដឹកនាំដ៏ជោគជ័យ តែងតែផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់គាត់លើវត្ថុបំណងទូទៅចំនួនបួន ៖

១-លើកកម្ពស់យ៉ាងខ្លាំងក្លាលើដំណើរការរៀន និងបង្រៀន ដើម្បីសម្របសម្រួលសមិទ្ធផលសិក្សាសម្រាប់កុមារទាំងអស់។

២-បណ្តុះគំនិតសហគមន៍ឲ្យចូលរួមយ៉ាងខ្លាំងក្លា ព្រោះថាពួកគាត់ទាំងអស់គឺជាផ្នែកមួយរបស់សាលារៀន។

៣-ផ្តល់តម្លៃ និងពង្រីកសមាមាត្រស្ថានភាពសង្គមសេដ្ឋកិច្ចរបស់កុមារ។

៤-លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវប្បធម៌អប់រំរបស់គ្រួសារ។

គ្រូបង្រៀន គឺជាចំណុចស្នូលចំពោះកំណែទម្រង់សាលារៀន។ ដូចនេះ ជោគជ័យនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុងបរិបទកំណែទម្រង់ គឺអាស្រ័យលើសមត្ថភាពរបស់គ្រូបង្រៀនដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធនោះ។ នៅប្រទេសកំពុងអភិវឌ្ឍជាច្រើន គ្រូបង្រៀនក្នុងកម្រិតមួយដ៏ខ្ពស់កំពុងត្រូវការកម្រិតអប់រំ និងបំប៉នចាំបាច់ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងដំណើរការកំណែទម្រង់សាលារៀន។ បន្ថែមលើនេះដោយសារមូលហេតុជាច្រើនបានធ្វើឲ្យសីលធម៌ និងការលើកទឹកចិត្តគ្រូបង្រៀនក្នុងប្រទេសទាំងនោះនៅមានកម្រិតទាបនៅឡើយ។ ដើម្បីឲ្យកំណែទម្រង់សាលារៀនប្រព្រឹត្តទៅបានជោគជ័យ ប្រការសំខាន់គឺត្រូវរៀបចំកម្មវិធីបំប៉ន បណ្តុះបណ្តាល និងផ្តល់យោបល់ឲ្យបានល្អ ដើម្បីកសាងភាពប៉ិនប្រសព្វពង្រឹងសមត្ថភាព និងកែលម្អសីលធម៌របស់គ្រូបង្រៀន។ ការងារនេះក៏ត្រូវរួមផងដែរនូវការបណ្តុះបណ្តាល និងវិក្រឹតការដែលមានគុណភាពខ្ពស់សម្រាប់គ្រូបង្រៀន ដើម្បីពួកគាត់អាចមានលទ្ធភាពបំពេញការងារប្រកបដោយប្រសិទ្ធភាពដែលផ្អែកលើគោលការណ៍សិស្សមជ្ឈមណ្ឌល និងគរុកោសល្យ ដ៏ទាក់ទាញដែលជាបេះដូងនៃកម្មវិធីសាលាកុមារមេត្រី។

ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការងារគុណភាព។ តាមរយៈស្វ័យវាយតម្លៃជាប្រព័ន្ធ បុគ្គលិកទាំងអស់នឹងបានយល់ច្បាស់អំពីអ្វីដែលជាអាទិភាព និងត្រូវអភិវឌ្ឍ ត្រូវធ្វើនៅពេលណា ត្រូវធ្វើតាមវិធីអ្វីខ្លះ ហើយអ្នកណាខ្លះជាអ្នកទទួលខុសត្រូវលើកិច្ចការទាំងនោះ។ នាយក

សាលារៀន បុគ្គលិក កុមារ និងសិស្ស ក៏ដូចជាមាតាបិតាសិស្សផងដែរ ត្រូវការជាចាំបាច់នូវជំនួយ តាមរយៈការផ្ដល់ព័ត៌មានត្រឡប់ និងទិន្នន័យដើម្បីបង្ហាញគុណភាព។ ក្នុងសាលារៀនមួយដែលចង់ឲ្យមានការប្រែប្រួលស្វ័យវាយតម្លៃត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់ រួមទាំងបុគ្គលម្នាក់ៗ ក្រុម និងស្ថាប័នទាំងមូលតែម្ដង។

## ៥.២-ថ្នាក់ក្រុង ស្រុក ខណ្ឌ

ក្នុងទសវត្សនៃបេសកកម្មរបស់ខ្លួនកន្លងមក អង្គការយូនីសែហ្វ (UNICEF) បានធ្វើឲ្យកម្មវិធីសាលាកុមារមេត្រីក្លាយទៅជាមធ្យោបាយដើម្បីជួយ និងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារទាំងអស់។ កម្មវិធីនេះ អាចចាត់ទុកបានថាជាកញ្ចប់ដំណោះស្រាយ និងជាឧបករណ៍គ្រប់ជ្រុងជ្រោយមួយ ដើម្បីទាញយកអន្តរាគមន៍ដ៏ទូលំទូលាយសម្រាប់ការងារគុណភាពអប់រំ។ ក្នុងនាមអ្នកគាំទ្រដ៏សំខាន់ម្នាក់ចំពោះកម្មវិធីនេះ អង្គការយូនីសែហ្វ (UNICEF) បានផលិតគោលការណ៍ណែនាំសម្រាប់ជាឯកសារយោង និងសៀវភៅណែនាំប្រតិបត្តិដើម្បីជួយដល់ការអនុវត្តគោលនយោបាយសាលាកុមារមេត្រី។

កិច្ចខិតខំប្រឹងប្រែងក្នុងការងារអប់រំ មិនមែនត្រឹមតែទទួលកុមារឲ្យចូលក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការកែលម្អគុណភាពនៃការសិក្សាទាំងមូល ព្រមទាំងបង្ហាញឲ្យឃើញអំពីបញ្ហាប្រឈមទាំងឡាយចំពោះអ្នកចូលរួម។ ប្រសិនបើបញ្ហាគុណភាព និងការចូលរៀនត្រូវបានដោះស្រាយ នោះកុមារដែលកំពុងនៅក្នុងសាលារៀនទំនងជាអាចបន្តការសិក្សារបស់គេតទៅទៀត រហូតដល់ចប់ភូមិសិក្សាពេញលេញ ព្រមទាំងអាចទទួលបានលទ្ធផលសិក្សាល្អ ដូចការរំពឹងទុកទៀតផង។

គោលបំណងរបស់កម្មវិធីកុមារមេត្រី គឺជំរុញសាលារៀន និងប្រព័ន្ធអប់រំឲ្យមានការរីកចម្រើនឈានឆ្ពោះទៅរកស្តង់ដារគុណភាព បង្ហាញអំពីកត្តាទាំងឡាយដែលជះឥទ្ធិពលលើសុខមាលភាព និងសិទ្ធិរបស់កុមារដែលជាអ្នកសិក្សា និងជាអ្នកទទួលផលជាចម្បងពីការបង្រៀន។ ស្តង់ដារគុណភាព គឺត្រូវបង្កលក្ខណៈដល់កុមារទាំងអស់អាចចូលរៀនបន្តការសិក្សាពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត និងបញ្ចប់ភូមិសិក្សាតាមកាលកំណត់។ ទន្ទឹមនឹងនោះ គឺផ្ដល់បទពិសោធន៍អប់រំល្អៗដល់សិស្សដែលអាចជំនះអភិវឌ្ឍ និងសម្រេចទៅតាមសក្ដានុពលរបស់ពួកគេ។ ចំណងទាក់ទងរវាងសាលាកុមារមេត្រី និងសហគមន៍របស់ខ្លួនមានសារៈសំខាន់ខ្លាំងណាស់។ សាលាកុមារមេត្រីស្ថិតនៅក្នុងសហគមន៍ ហើយត្រូវមានទំនាក់ទំនងរវាងគ្នានឹងគ្នា។

ជាទូទៅ សាលាកុមារមេត្រី និងបរិយាកាសសិក្សា គប្បីត្រូវបានពិនិត្យតាមដាន និងវាយតម្លៃ ហើយលទ្ធផលដែលបានមក គឺជាភស្តុតាងចាំបាច់សម្រាប់ក្រសួងក្នុងការវាយតម្លៃប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិដើម្បីជួយឲ្យសម្រេចបានវត្ថុបំណង។

ដូចនេះ ជោគជ័យរបស់សាលាកុមារមេត្រីអាចវាស់វែងបានតាមរយៈសមត្ថភាពក្នុងការជួយគាំទ្រដល់វត្ថុបំណង និងគោលដៅដែលបានកំណត់។ ចំណុចដៅជាក់លាក់ និងសូចនាករសម្រាប់វាស់វែងប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងសមធម៌របស់កម្មវិធីសាលាមេត្រី គឺជាការសំខាន់ណាស់។ ប្រសិទ្ធភាពត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបលទ្ធផលជាក់ស្ដែងទៅនឹងចំណុចដៅ។ ការប្រើប្រាស់សូចនាករដែលបានពីការវាយតម្លៃផលសម្រេចនៃកម្មវិធីសាលាកុមារមេត្រី អាចបង្ហាញថាកម្មវិធីកំពុងផ្ដល់ការអប់រំប្រកបដោយគុណភាពដល់កុមារទាំងអស់។

តាមរយៈការពិនិត្យតាមដាន និងវាយតម្លៃលើផែនការកែលម្អសាលារៀន និងកម្មវិធីសាលាកុមារមេត្រី គ្រូបង្រៀនម្នាក់ៗ សាលារៀន និងសហគមន៍ អាចកំណត់បានពីចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចត្រូវកែលម្អដែលកើតមានឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ ដើម្បីសម្រេចបានលទ្ធផលរួមទាក់ទងនឹងគុណភាពអប់រំទៅតាមផ្លូវច្បាប់ បញ្ញត្តិសាលាកុមារមេត្រី ត្រូវតែមានចំណងទាក់ទងទៅនឹងការពិនិត្យតាមដានពីខាងក្រៅតាមរយៈខ្សែបណ្តោយរបស់ក្រសួង។ មានន័យថា លក្ខណវិនិច្ឆ័យសម្រាប់ពិនិត្យតាមដានពីខាងក្រៅ និងស្វ័យវាយតម្លៃត្រូវតែមានទំនាក់ទំនងរវាងគ្នា ប៉ុន្តែអាទិភាពរបស់មូលដ្ឋានត្រូវតែលើកមកបង្ហាញនៅក្នុងការងារស្វ័យវាយតម្លៃ និងការអង្កេតពីខាងក្រៅផងដែរ។

តាមនិយមន័យ ជោគជ័យរបស់សាលាកុមារមេត្រី គឺបានមកពីការកែលម្អដោយខ្លួនឯង ពីព្រោះថា ការកែលម្អគុណភាពមិនអាចកើតចេញពីខាងក្រៅមកបានទេ។ តាមរយៈការវាយតម្លៃសាលារៀន និងប្រព័ន្ធ អប់រំ ទម្រង់របាយការណ៍ដែលបង្ហាញពីការទទួលខុសត្រូវចំពោះមុខមួយនឹងត្រូវបានបង្កើត និងអនុវត្ត។ តាមរយៈការសិក្សាតាមករណី និងការចងក្រងឯកសារដទៃទៀតសាលារៀនមិនត្រឹមតែទទួលបានលទ្ធផល បែបបរិមាណប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដឹងទៀតថាតើលទ្ធផលទាំងនេះកើតចេញមកបានយ៉ាងដូចម្តេច។

សារសំខាន់នៃការពិនិត្យតាមដាន និងវាយតម្លៃ គឺការផ្តល់ឱកាសដល់គ្រូបង្រៀន និងនាយកសាលារៀនបានពិភាក្សាគ្នាជាមួយសមាជិកដទៃទៀត តាមរយៈការប្រើប្រាស់វិធីសាស្ត្ររបស់សាលាកុមារមេត្រីសំដៅកែលម្អចំណុចដែលកំពុងអសកម្ម។

*__តួនាទីក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ__ (DTMT)

- ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងដែលមានសមាសភាពមកពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ប្រធានកម្រង ប្រធានក្រុមបច្ចេកទេស
- វាយតម្លៃលទ្ធផលការងារសាលារៀន និងថ្នាក់រៀនសម្រេចបាន
- ជួយ និងកែលម្អមុខសញ្ញាទាំងពីរឲ្យកាន់តែប្រសើរ តាមរយៈការផ្តល់អនុសាសន៍ក្នុងពេលចុះពិនិត្យតាមដាន ឬ ការចុះសម្របសម្រួលឲ្យធ្វើផ្ទាល់
- ប្រើប្រាស់ព័ត៌មាននានាធ្វើជាមូលដ្ឋាននៃការវិភាគ វាយតម្លៃសាលារៀនតាមទស្សនអាជីព និងផ្អែកលើលទ្ធផលស្វ័យវាយតម្លៃរបស់សាលារៀនជាមូលដ្ឋាន (ជាអ្នកវាយតម្លៃលើកទី២)។

## ៦-អធិការកិច្ចផ្ទៃក្រៅ



អគ្គនាយកដ្ឋានអប់រំ និងអគ្គាធិការដ្ឋាន គឺជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យតាមដានអប់រំ[17]។ ក្នុងអគ្គាធិការដ្ឋាន មានអង្គភាពពីរដែលមានភារកិច្ចត្រួតពិនិត្យ គឺអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង នាយក ដ្ឋានធានាគុណភាពអប់រំ (នា.ធគអ)[18]។

១-នាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកអនុវត្តអធិការកិច្ចតាមប្រធានបទ។

២-នាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដានជាប្រចាំ និងត្រួត ពិនិត្យ ដំណើរការអធិការកិច្ចតាមកាលកំណត់។ នេះមានន័យថា នាយកដ្ឋានធានាគុណភាពអប់រំ ទទួលខុសត្រូវ លើការពិនិត្យឡើងវិញជាប្រចាំនៃដំណើរការអធិការកិច្ច ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត ដំណើរការអធិការកិច្ចរបស់អធិការនៅតាមរាជធានី ខេត្ត។ ការពិនិត្យឡើងវិញ អាចធ្វើទៅបានតាមរយៈការ រៀបចំសិក្ខាសាលាស្តីការអនុវត្ត ការផ្តល់យោបល់ និងណែនាំចំពោះអធិការ។

៣-នាយកដ្ឋានធានាគុណភាពអប់រំ ត្រូវធ្វើការវិភាគ និងរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើ ៖

- ការងារអធិការកិច្ចតាមប្រធានបទដែលបានបញ្ចប់
- ការងារអធិការកិច្ចតាមកាលកំណត់ដែលបានបញ្ចប់
- ការវិភាគផ្នែកស្ថិតិ។

៤-នាយកដ្ឋានធានាគុណភាពអប់រំ ត្រូវធ្វើសេចក្តីសន្និដ្ឋានផ្នែកដែលត្រូវកែលម្អ។ នាយកដ្ឋាន ធានាគុណភាពអប់រំ ត្រូវធ្វើការសម្របសម្រួលជាមួយនាយកដ្ឋានជំនាញដែលពាក់ព័ន្ធ នាយកដ្ឋានផែនការ (ផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (QEMIS)) និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

ចំណេះដឹង និងបទពិសោធន៍ពេញលេញដែលនាយកដ្ឋានធានាគុណភាពអប់រំទទួលបានពីដំណើរ ការអធិការកិច្ចទាក់ទងនឹងស្ថានភាពអប់រំរបស់ប្រទេស នឹងដើរតួនាទីយ៉ាងសំខាន់ដល់ការអភិវឌ្ឍកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត ការងារប្រឡង និងតេស្ត និងផ្តល់ជាបទពិសោធន៍អនុវត្តល្អៗក្នុងការបង្រៀន។

## ៦.១-អធិការកិច្ចតាមប្រធានបទ

**និយមន័យ[19]៖**

**អធិការកិច្ចតាមប្រធានបទ** គឺជាការពិនិត្យ និងវាយតម្លៃជាលក្ខណៈប្រព័ន្ធលើគុណភាពរបស់កិច្ចការ មួយក្នុងប្រធានបទមួយដែលបានកំណត់។ ការវាយតម្លៃត្រូវផ្អែកលើការបកស្រាយទៅតាមគោលបំណង ថ្នាក់ជាតិ និងគោលការណ៍ណែនាំគាំទ្រដោយលទ្ធផលស្រាវជ្រាវ និងការអនុវត្តល្អបំផុត។ លទ្ធផលដែល បានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះដែលមានដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ។

[17]ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា៩

[18]រាជរដ្ឋាភិបាលកម្ពុជាអនុក្រឹត្យស្តីពីការរៀបចំ និងកាប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជននិងកីឡា លេខ៨៩.អនក្រ.បកចុះថ្ងៃទី០៩ខែមិថុនាឆ្នាំ២០០៩ មាត្រា៧

[19]អធិការដ្ឋានអប់រំស៊ុយអែត ក្របខណ្ឌធានាគុណភាពអប់រំ

នាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកទទួលខុសត្រូវលើការធ្វើអធិការកិច្ចតាមប្រធានបទនេះ។ អធិការកិច្ចតាមប្រធានបទនឹងជួយនាយកដ្ឋានធានាគុណភាពអប់រំ ពិនិត្យលើផ្នែកផ្សេងៗនៃកិច្ចការរបស់សាលារៀនក្នុងលក្ខណៈលម្អិត។ ការធ្វើអធិការកិច្ចអាចផ្ដោតលើការប្រើប្រាស់កម្មវិធីសិក្សាគោលដៅ និងគោលការណ៍ណែនាំ ព្រមទាំងផ្ដោតលើទិដ្ឋភាពផ្សេងៗទៀតនៃគុណភាព។ វត្ថុបំណងនៃការធ្វើអធិការកិច្ចគឺដើម្បីទទួលបាននូវការអនុវត្តកាន់តែប្រសើរឡើងក្នុងសាលារៀនដែលបានពិនិត្យ រួមជាមួយនឹងការផ្ដោតលើលទ្ធផលសិក្សារបស់សិស្ស ហើយប្រមូលចំណេះដឹងល្អៗដើម្បីផ្សព្វផ្សាយទៅសាលារៀនដទៃទៀតនៃប្រទេស និងជូនក្រសួងផងដែរ។

ភាពញឹកញាប់ និងខ្លឹមសារនៃការធ្វើអធិការកិច្ចតាមប្រធានបទ គឺអាស្រ័យទៅលើប្រធានបទ និងភាពបន្ទាន់របស់ប្រធានបទដែលត្រូវធ្វើការពិនិត្យនោះ។ អធិការកិច្ចតាមប្រធានបទ គឺជាការធ្វើអធិការកិច្ចផ្ដោតលើហានិភ័យដែលនាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកជ្រើសរើសសម្រាប់មួយឆ្នាំក្រោមការផ្ដល់យោបល់ពីសំណាក់ថ្នាក់ដឹកនាំក្រសួង។ នាយកដ្ឋានធានាគុណភាពអប់រំ គប្បីរៀបចំផែនការធ្វើអធិការកិច្ចតាមប្រធានបទពី២ ទៅ៥ប្រធានបទក្នុងមួយឆ្នាំលើសាលារៀនចំនួនពី១៥ ទៅ៤០ សម្រាប់ការចុះធ្វើអធិការកិច្ចម្ដងៗ តាមរយៈការជ្រើសរើសដោយមិនបានគ្រោងទុក និងអាស្រ័យលើធនធានរបស់នាយកដ្ឋានដែលមាន។ សាលារៀនដែលត្រូវបញ្ចូលក្នុងការធ្វើអធិការកិច្ចតាមប្រធានបទ ត្រូវជ្រើសរើសផ្អែកជាសំខាន់លើការវាយតម្លៃប្រចាំឆ្នាំលើលទ្ធផលសិក្សារបស់សិស្សដែលទទួលបានពី QEMIS។ បន្ថែមលើនេះចំណេះដឹង និងបទពិសោធន៍ដែលបានពីការធ្វើអធិការកិច្ចតាមដំណាក់កាលពីបណ្ដាខេត្ត និងសាលារៀន ក៏អាចត្រូវបានយកមកប្រើប្រាស់ផងដែរសម្រាប់ដំណើរការជ្រើសរើស។

ឧទាហរណ៍ប្រធានបទសម្រាប់ការធ្វើអធិការកិច្ចតាមប្រធានបទមានដូចជា តើសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃរបស់គ្រូបង្រៀនលើចំណេះដឹងរបស់សិស្សយ៉ាងដូចម្ដេច ការប្រៀបធៀបមូលហេតុនៃការបោះបង់ការសិក្សានៅតំបន់ផ្សេងៗគ្នា វិធីសាស្ត្រដែលសាលារៀនប្រើជាមួយសិស្សដែលមានការលំបាកក្នុងការសិក្សា តួនាទីរបស់នាយកសាលាដែលជាអ្នកដឹកនាំអប់រំ និងគរុកោសល្យ ឬ ធ្វើការប្រៀបធៀបខ្លឹមសារ និងទម្រង់នៃការបង្រៀនមុខវិជ្ជាណាមួយដូចជា ភាសាអង់គ្លេស រូបវិទ្យា ឬ គណិតវិទ្យាជាដើម។

នាយកដ្ឋានធានាគុណភាពអប់រំ ធ្វើការវាយតម្លៃគុណភាពសកម្មភាពមួយ ថាតើសាលារៀនបានគ្រប់គ្រងសកម្មភាពនោះឲ្យមានដំណើរការយ៉ាងដូចម្ដេច ដើម្បីឈានទៅសម្រេចបានវត្ថុបំណងថ្នាក់ជាតិ។ ក្រៅពីច្បាប់ និងគោលការណ៍ដែលមានការសិក្សាស្រាវជ្រាវលើការអនុវត្តដែលល្អបំផុតក្នុងពេលបច្ចុប្បន្ន ក៏ជាភស្តុតាងសំខាន់ណាស់ដែរសម្រាប់ការធ្វើអធិការកិច្ចប្រភេទនេះ។

ជារឿយៗអធិការពីនាយកដ្ឋានធានាគុណភាពអប់រំ ប្រមូលឯកសារសរសេរដៃ និងធ្វើទស្សនកិច្ចសាលារៀន អង្កេតការបង្រៀន និងធ្វើសម្ភាសជាមួយមន្ត្រីសំខាន់ៗ និងសិស្ស ប៉ុន្តែវិធីនេះអាចធ្វើខុសៗគ្នាអាស្រ័យលើប្រធានបទអ្វីដែលយើងចង់ធ្វើការអង្កេតស្រាវជ្រាវ។ ការរៀបចំអធិការកិច្ចតាមប្រធានបទត្រូវរួមបញ្ចូលនូវការកសាងក្របខណ្ឌ និងឧបករណ៍សម្រាប់អធិការកិច្ចបច្ចុប្បន្ន ឧទាហរណ៍រៀបចំកម្មវិធីធ្វើអង្កេត ដើម្បីប្រើប្រាស់ក្នុងការធ្វើអធិការកិច្ចលើប្រធានបទជាក់លាក់មួយជាដើម។

សាលារៀនដែលបានទទួលការធ្វើអធិការកិច្ច អាចទាញផលប្រយោជន៍ពីលទ្ធផលក្នុងរបាយការណ៍ដែលនាយកដ្ឋានធានាគុណភាពអប់រំ បានបូកសរុបបន្ទាប់ពីការធ្វើអធិការកិច្ចលើប្រធានបទណាមួយ។ នាយកដ្ឋានធានាគុណភាពអប់រំ ក៏ត្រូវសរសេររបាយការណ៍ពិសេសមួយសម្រាប់ប្រធានបទនីមួយៗ ដោយ

សង្ខេបលទ្ធផលពីសាលារៀនទាំងអស់ក្នុងសំណាកគំរូ។ ក្នុងរបាយការណ៍នេះនាយកដ្ឋានធានាគុណភាពអប់រំនឹងសង្ខេប និងវិភាគលើចំណុចអភិវឌ្ឍដែលរកឃើញក្នុងពេលធ្វើអធិការកិច្ចសាលារៀន។ របាយការណ៍ក៏រៀបរាប់ផងដែរនូវកត្តាជោគជ័យទាំងឡាយ ព្រមទាំងលើកមកបង្ហាញនូវឧទាហរណ៍ល្អៗ ដើម្បីអ្នកដទៃទៀតអាចទាញយកផលប្រយោជន៍ពីបទពិសោធន៍វិជ្ជមានទាំងនោះបាន។

ប្រសិនបើនាយកដ្ឋានធានាគុណភាពអប់រំ បានកំណត់ផ្នែកសំខាន់ៗនៃការអភិវឌ្ឍ នាយកដ្ឋានធានាគុណភាពអប់រំ អាចធ្វើការតាមដានសកម្មភាពដែលបានអនុវត្ត និងបានគ្រោងទៅតាមការចាំបាច់។ ការបន្តតាមដានអាចយកទៅអនុវត្តផងដែរក្នុងការធ្វើអធិការកិច្ចតាមកាលកំណត់ នៅពេលដែលអធិការថ្នាក់ខេត្តទៅធ្វើអធិការកិច្ចសាលារៀន ហើយប្រើប្រាស់អនុសាសន៍ ពីនាយកដ្ឋានធានាគុណភាពអប់រំ។

### ៦.១.១-ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមប្រធានបទ

របាយការណ៍អធិការកិច្ចថ្នាក់ខេត្តមានពីរប្រភេទគឺ ៖

១-របាយការណ៍សាលារៀន

២-របាយការណ៍ថ្នាក់ជាតិ

សាលារៀនដែលបានធ្វើអធិការកិច្ចរួច នឹងទទួលបានរបាយការណ៍លទ្ធផលមួយច្បាប់ ដែលមានរៀបរាប់អំពីការវាយតម្លៃលើផ្នែកដែលអធិការកិច្ចបានផ្តោត។ អនុសាសន៍ក្នុងរបាយការណ៍នឹងត្រូវប្រើប្រាស់ជាចំណុចចាប់ផ្តើមសម្រាប់កែលម្អគុណភាពប្រតិបត្តិការ។ ជាការសំខាន់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដែលគ្រប់គ្រងសាលារៀនទាំងនោះ ក៏ត្រូវទទួលបានរបាយការណ៍សាលារៀនផងដែរ ដើម្បី DTMT អាចប្រើប្រាស់អនុសាសន៍ដែលបានចុះក្នុងរបាយការណ៍សម្រាប់ជាមូលដ្ឋានណែនាំ និងផ្តល់យោបល់។

បន្ទាប់ពីអធិការកិច្ចតាមប្រធានបទ ត្រូវបានបញ្ចប់នៅគ្រប់សាលារៀនទាំងអស់ដែលបានជ្រើសរើសនៅទូទាំងប្រទេស មន្ត្រីនាយកដ្ឋានធានាគុណភាពអប់រំ ដែលបានចុះធ្វើអធិការកិច្ចលើប្រធានបទនេះនឹងរួមគ្នាធ្វើរបាយការណ៍ថ្នាក់ជាតិមួយ។ រាល់ស្ថានភាពទាំងអស់នឹងត្រូវបានបរិយាយ និងវិភាគ ហើយសេចក្តីសន្និដ្ឋាន និងសំណូមពរផ្សេងៗ ក៏នឹងត្រូវរំលេចផងដែរក្នុងរបាយការណ៍នោះសម្រាប់សកម្មភាពនាពេលអនាគត។ របាយការណ៍ថ្នាក់ជាតិនឹងត្រូវផ្ញើទៅមន្ទីរអយក.ទាំងអស់ក្នុងប្រទេស និងជូនថ្នាក់ដឹកនាំក្រសួងផងដែរ។ បន្ថែមលើនេះ របាយការណ៍ក៏នឹងត្រូវផ្សព្វផ្សាយក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (QEMIS) ផងដែរ។

## ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមប្រធានបទ

| ប្រភេទរបាយការណ៍ | អ្នកទទួល | | | | |
|---|---|---|---|---|---|
| របាយការណ៍សាលារៀន | សាលារៀន | DOE[20] | POE[21] | Q-EMIS | |
| របាយការណ៍ថ្នាក់ជាតិ | | | POE[22] | Q-EMIS | ថ្នាក់ដឹកនាំ |

[20] DOE ទទួលខុសត្រូវសាលារៀនដែលបានធ្វើអធិការកិច្ច

[21] POE ទទួលខុសត្រូវសាលារៀនដែលបានធ្វើអធិការកិច្ច

[22] POEទូទាំងប្រទេស

## ៦.២-អធិការកិច្ចតាមកាលកំណត់

**និយមន័យ[23]៖**

**អធិការកិច្ចតាមកាលកំណត់** គឺជាការពិនិត្យ និងវាយតម្លៃសាលារៀនទាំងអស់ជាប្រព័ន្ធ ដើម្បីធានាថាពួកគេបានគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។ ការវាយតម្លៃគឺត្រូវផ្អែកលើការបកស្រាយបទប្បញ្ញត្តិរបស់ជាតិ។ លទ្ធផលដែលបានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះដែលមានដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ។

អធិការកិច្ចតាមកាលកំណត់នឹងត្រូវអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥ រាជធានី ខេត្ត និងក្រុមអធិការរបស់ពួកគេ។ អធិការកិច្ចតាមកាលកំណត់ នឹងប្រមូលបានព័ត៌មានទូទៅនៃប្រព័ន្ធសាលារៀន និងសមត្ថភាពរបស់សាលារៀនក្នុងការសម្រេចបេសកកម្មថ្នាក់ជាតិ។

ឧបករណ៍ទាំងអស់សម្រាប់ការធ្វើអធិការកិច្ច ត្រូវផ្អែកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ កម្មវិធីសិក្សា អនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលនយោបាយថ្នាក់ជាតិ ផ្សេងទៀតនៃវិស័យអប់រំនៅកម្ពុជា។ អធិការកិច្ចតាមកាលកំណត់ ត្រូវផ្តោតលើផ្នែកទាំងឡាយដែលមានសារសំខាន់សម្រាប់ការអភិវឌ្ឍន៍ និងការកែលម្អសាលារៀន។ គោលបំណងនៃការធ្វើអធិការកិច្ចនេះ គឺដើម្បីទទួលបាននូវការអនុវត្តដែលកាន់តែប្រសើរឡើង នៅក្នុងសាលារៀនដែលបានពិនិត្យជាមួយនឹងការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងសុខមាលភាពសង្គមហើយយកចំណេះដឹងទាំងនោះទៅផ្សព្វផ្សាយដល់សាលារៀនដទៃទៀតនៅក្នុងប្រទេស និងជូនក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

នាយកដ្ឋានធានាគុណភាពអប់រំ នឹងទទួលខុសត្រូវត្រួតពិនិត្យលើបេសកកម្មអធិការកិច្ចទាំង ២៥ រាជធានី ខេត្ត ដោយផ្តល់សៀវភៅណែនាំវាយតម្លៃឧបករណ៍សម្រាប់ប្រើប្រាស់ ឯកសារសម្រាប់ការរាយការណ៍ និងតម្រូវការវិសាលភាពការងារអធិការកិច្ច។ ជាទូទៅអធិការកិច្ចតាមកាលកំណត់ត្រូវធ្វើឡើងក្នុងលក្ខណៈដូចគ្នាសម្រាប់រយៈពេលយូរហើយការផ្លាស់ប្តូរដំណើរការ និងសៀវភៅណែនាំវាយតម្លៃនឹងមិនធ្វើជាញឹកញាប់ទេ។

ក្រុមអធិការនេះមិនមែនជាក្រុមអធិការតាមមុខវិជ្ជាទេ។ ពួកគាត់ត្រូវបានបណ្តុះបណ្តាលដើម្បីពិនិត្យលើគ្រប់ផ្នែកទាំងអស់ មានន័យថាអធិការជំនាញមុខវិជ្ជាណាក៏ដោយ ដូចជាអធិការផ្នែកភាសាជាដើម ក៏អាចធ្វើសម្ភាសន៍ និងសង្កេតគ្រូបង្រៀនមុខវិជ្ជាផ្សេងទៀតបានដែរ។ នេះគឺជាការផ្តោតលើការបង្រៀន និងការរៀនទាំងមូលដែលអនុវត្តចំពោះគ្រូទាំងអស់មិនគិតពីមុខវិជ្ជានោះទេ[24]។

ជាទូទៅ អធិការនៅតាមរាជធានី ខេត្តជាអ្នកប្រមូលឯកសារ ពិនិត្យសាលារៀន សង្កេតការបង្រៀន និងធ្វើសម្ភាសន៍ជាមួយបុគ្គលិកសំខាន់ៗ និងសិស្សានុសិស្ស។ មុនពេលចុះទៅសាលារៀនមួយ ក្រុមអធិការត្រូវរៀបចំសិក្សាអង្កេតលើឯកសារ និងទិន្នន័យអំពីសាលារៀននោះជាមុនសិន។ ក្រុមអធិការក៏ត្រូវប្រើប្រាស់ផងដែរនូវឯកសារលំណែនាំអធិការកិច្ចរបស់កម្មវិធីសាលាកុមារមេត្រី និងទិន្នន័យអំពីសមិទ្ធផលសិក្សារបស់សិស្សដែលមាននៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (QEMIS)។ ប្រសិនបើនាយកដ្ឋាន

---

[23] អធិការដ្ឋានអប់រំស៊ុយអែត ក្របខណ្ឌធានាគុណភាពអប់រំ

[24] កិច្ចប្រជុំគណៈកម្មការដឹកនាំកម្មវិធី ភ្នំពេញ, ខែធ្នូ ២០១២

ធានាគុណភាពអប់រំបានធ្វើអធិការកិច្ចតាមប្រធានបទ (thematic inspection) នៅសាលារៀនរួចហើយ របាយការណ៍នោះក៏អាចយកមកប្រើប្រាស់ដើម្បីទទួលបានព័ត៌មានអំពីចំណុចខ្លាំង និងចំណុចខ្សោយ របស់សាលារៀនដែលនឹងត្រូវចុះធ្វើ អធិការកិច្ចផងដែរ។

**អធិការកិច្ចតាមកាលកំណត់ អាចអនុវត្តទៅលើផ្នែកសំខាន់ៗចំនួន៤ដូចខាងក្រោម ៖**

- ការដឹកនាំ និងគ្រប់គ្រង
- ការបង្រៀន និងរៀន
- សមិទ្ធផលសិក្សារបស់សិស្ស
- គុណភាពការងារ ស្វ័យវាយតម្លៃសាលារៀន។

អធិការធ្វើការវាយតម្លៃលើផ្នែកដែលបានរៀបរាប់ខាងលើ ចាប់ពីរបៀបគ្រប់គ្រងរបស់សាលារៀន រហូតដល់ការសម្រេចបាននូវគោលបំណងថ្នាក់ជាតិ។

### ៦.២.១-ភាពញឹកញាប់នៃការធ្វើអធិការកិច្ចតាមកាលកំណត់

ភាពញឹកញាប់ និងខ្លឹមសារនៃការធ្វើអធិការកិច្ចទៀងទាត់ គឺអាស្រ័យលើកត្តាពីរគឺ ៖

១-តើសាលារៀនដែលត្រូវធ្វើអធិការកិច្ចទាំងអស់ ត្រូវការធ្វើអធិការកិច្ចក្នុងវិធីដូចគ្នាឬទេ?

២-ចំនួនអធិការ។

អធិការកិច្ចតាមកាលកំណត់ គឺជាការធ្វើអធិការកិច្ចផ្តោតលើហានិភ័យ ហើយថ្នាក់ខេត្តជាអ្នករៀបចំផែនការអធិការកិច្ច និងជ្រើសរើសសាលារៀន ដោយសហការជាមួយនាយកដ្ឋានធានាគុណភាពអប់រំ។ ជាទូទៅ ការធ្វើអធិការកិច្ចសាលារៀនមួយ គប្បីចំណាយពេល១ ឬ ២ថ្ងៃ ជាមួយអធិការពីររូប។

ក្នុងកំឡុងពេលអន្តរកាល រហូតដល់ក្រសួងអាចពង្រីកបរិមាណអធិការគ្រប់គ្រាន់ អធិការកិច្ចតាមកាលកំណត់គប្បីធ្វើក្នុងសភាពខុសៗគ្នា មានន័យថា សាលារៀនទាំងអស់មិនត្រូវបានធ្វើអធិការកិច្ចក្នុងវិធីដូចៗគ្នានោះទេ។ ខាងក្រោមនេះ ជាគំរូមួយដែលផ្តោតលើការអនុវត្តប្រព័ន្ធស្វ័យវាយតម្លៃសម្រាប់សាលារៀនទាំងអស់ ៖

**ក.**នៅពេលរៀបចំផែនការអធិការកិច្ចរបស់ស្រុក (ផែនការអធិការកិច្ចប្រចាំឆ្នាំរបស់ PoE) មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំវិភាគបញ្ហា ដើម្បីជ្រើសរើសយកសាលារៀនចំនួន៥0 ភាគរយ នៃសាលារៀនទាំងអស់ក្នុងស្រុកសម្រាប់ការធ្វើអធិការកិច្ច។

**ខ.**មុនពេលចាប់ផ្តើមធ្វើអធិការកិច្ចនៅក្នុងក្រុង ស្រុក ខណ្ឌត្រូវអញ្ជើញនាយកសាលារៀនទាំងអស់ នៅក្នុងក្រុង ស្រុក ខណ្ឌ មកចូលរួមក្នុងសិក្ខាសាលាមួយ។ ក្រុមអធិការនឹងជម្រាបជូនអំពីការសម្រេចចិត្តរបស់ពួកគាត់លើការជ្រើសរើសសាលារៀន ហើយជាមួយគ្នានេះធ្វើការបង្ហាញជូនអំពីមូលដ្ឋានសម្រាប់ការវាយតម្លៃការធ្វើអធិការកិច្ចតាមកាលកំណត់។ នាយកសាលារៀនដែលមិនត្រូវបានធ្វើអធិការកិច្ច ត្រូវធ្វើស្វ័យវាយតម្លៃ សាលារៀនរបស់ខ្លួនដោយមានឯកសារណែនាំជាជំនួយ។ បន្ទាប់មក ត្រូវកំណត់កាលបរិច្ឆេទសម្រាប់សិក្ខា សាលាបន្ទាប់ទៀត។

**គ.**បន្ទាប់ពីក្រុមអធិការបានបញ្ចប់ការងារអធិការកិច្ចរបស់ខ្លួនក្នុងក្រុង ស្រុក ខណ្ឌហើយនាយកសាលាទាំងអស់ នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសិក្ខាសាលាលើកទីពីរដើម្បីបង្ហាញ និងពិភាក្សាលើលទ្ធផលដែលបានមកពីការធ្វើអធិការកិច្ច ព្រមទាំងលទ្ធផលដែលធ្វើឡើងដោយស្វ័យវាយតម្លៃផងដែរ។ ចំណុចខ្លាំង

និងចំណុចខ្សោយត្រូវបានលើកឡើង ហើយក្រុមអធិការនឹងពន្យល់បំភ្លឺ ផ្តល់យោបល់ និងណែនាំដល់នាយកសាលាទាំងនោះ។

**ឃ**.ក្រុមអធិការត្រូវសរសេររបាយការណ៍សាលារៀនបន្ទាប់ពីធ្វើអធិការកិច្ចសាលារៀននីមួយៗ និងសរសេរកំណត់ហេតុនៃសិក្ខាសាលាលើកទីពីរដោយមានជំនួយពីការពិភាក្សា និងពីរបាយការណ៍ស្វ័យវាយតម្លៃសាលារៀន។ កំណត់ហេតុទាំងនេះត្រូវផ្សព្វផ្សាយរួមគ្នាជាមួយរបាយការណ៍របស់ក្រុង ស្រុក ខណ្ឌ។

ជាមួយនឹងគំរូនេះ អធិការថ្នាក់រាជធានី ខេត្តទាំងអស់(ប្រហែល១៣០នាក់) អាចធ្វើអធិការកិច្ចបានប្រហែល ៩០០សាលារៀនជារៀងរាល់ឆ្នាំ ដូចនេះក្នុងរយៈពេល៥ឆ្នាំ ៥០ភាគរយនៃសាលារៀន (៤ ៤៥២ សាលារៀន) នឹងត្រូវបានធ្វើអធិការកិច្ច។ ក្នុងពេលជាមួយគ្នានេះ សាលារៀនទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវអនុវត្តប្រព័ន្ធស្វ័យវាយតម្លៃសាលារៀនរបស់ខ្លួន។ ការធ្វើអធិការកិច្ចតាមបែបថ្មី គួរត្រូវបានអនុវត្តនៅអំឡុងខែតុលា ឆ្នាំ២០១៤ ប៉ុន្តែដោយសារមានតម្រូវការអនុវត្ត និងរៀបចំគំរូថ្មី យើងអាចចាត់ទុកថា ឆ្នាំដំបូងនៃការអនុវត្តនេះថាជាឆ្នាំសាកល្បងមួយ។ ដូច្នេះវដ្តដំបូងនៃការងារអធិការកិច្ចនេះអាចត្រូវពន្យារដល់ខែតុលា ឆ្នាំ២០២០។ សម្រាប់បច្ចុប្បន្នវដ្តនៃការធ្វើអធិការកិច្ចត្រូវមានរយៈពេល ៥ឆ្នាំ។

ចំនួនសាលាមត្តេយ្យ មិនត្រូវបានបញ្ចូលទៅក្នុងចំនួនសាលារៀនដែលបានគណនាខាងលើនេះទេ។ ការធ្វើអធិការកិច្ចសាលាមត្តេយ្យនឹងត្រូវធ្វើដោយនាយកដ្ឋានជំនាញទៅតាមនីតិវិធី ដែលបានធ្វើដូចបច្ចុប្បន្ន។

បើតាមផែនការសម្រាប់រយៈពេល៥ឆ្នាំបន្ទាប់(២០២០-២០២៥) កម្ពុជានឹងត្រូវបង្កើនចំនួនអធិការបន្ថែមទៀត។ ពេលនោះក្រសួងអាចជ្រើសយកជម្រើស ៖

ក-បង្កើនភាគរយនៃចំនួនសាលារៀនដែលត្រូវធ្វើអធិការកិច្ច ឬ

ខ-ជាមួយនឹងគំរូដូចគ្នានេះ បន្ថយវដ្តពេលអធិការកិច្ចមក៣ឆ្នាំវិញ ឬ

គ-រួមបញ្ចូលសាលាមត្តេយ្យទៅក្នុងការងារអធិការកិច្ចតាមកាលកំណត់របស់ថ្នាក់រាជធានី ខេត្ត។

| **ប្រភេទសាលារៀន** | **សាលារៀនរដ្ឋ** | **សាលារៀនឯកជន** | **សរុប** |
|---|---|---|---|
| សាលាមត្តេយ្យ | 2813 | 164 | **2977** |
| សាលារៀនបឋមសិក្សា | 6910 | 223 | **7133** |
| សាលារៀនអនុវិទ្យាល័យ | 1214 | 30 | **1244** |
| សាលារៀនវិទ្យាល័យ | 433 | 74 | **507** |
| សរុប | **11370** | **491** | **11861** |

### ៦.២.២-ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមកាលកំណត់

មានរបាយការណ៍បីប្រភេទនឹងត្រូវរៀបចំដោយអធិការថ្នាក់ខេត្ត៖

១-របាយការណ៍សាលារៀន

២-របាយការណ៍សង្ខេប

៣-ការវិភាគប្រចាំឆ្នាំ

រាល់សាលារៀនទាំងអស់ដែលបានធ្វើអធិការកិច្ច នឹងទទួលបានរបាយការណ៍លទ្ធផលនៅពេលធ្វើអធិការកិច្ចត្រូវបានបញ្ចប់។ សាលារៀននឹងទទួលបានការវាយតម្លៃលើផ្នែកដែលអធិការកិច្ចបានផ្តោត។ អនុសាសន៍ដែលមានចែងក្នុងរបាយការណ៍ នឹងត្រូវបានប្រើប្រាស់ជាចំណុចចាប់ផ្តើមសម្រាប់កែលម្អគុណភាពប្រតិបត្តិការ។ ជាការសំខាន់ដែលការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវទទួលនូវរបាយការណ៍សាលារៀនទាំងនោះដែរដើម្បីឲ្យក្រុម DTMT អាចប្រើប្រាស់អនុសាសន៍ដែលមានក្នុងរបាយការណ៍ធ្វើជាមូលដ្ឋានសម្រាប់ផ្តល់ការណែនាំ និងផ្តល់យោបល់។

រៀងរាល់ឆ្នាំបន្ទាប់ពីបញ្ចប់ការធ្វើអធិការកិច្ចសាលារៀនក្នុងក្រុង ស្រុក ខណ្ឌ អធិការថ្នាក់រាជធានី ខេត្តត្រូវផ្ញើរបាយការណ៍ដែលរៀបរាប់សង្ខេបនូវអនុសាសន៍នានាមក QEMIS។

រៀងរាល់ឆ្នាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត (POE) ត្រូវបង្ហាញរបាយការណ៍ដែលមានការវិភាគនូវគ្រប់អធិការកិច្ចដែលបានធ្វើនៅក្នុងរាជធានី ខេត្ត។

QEMIS នឹងរៀបចំមូលដ្ឋានទិន្នន័យមួយសម្រាប់ផ្ទុករបាយការណ៍ទាំងនោះ។ ព័ត៌មានជាច្រើននឹងអាចមើលឃើញដូចជា របាយការណ៍សាលារៀន របាយការណ៍សង្ខេបរបស់ក្រុង ស្រុក ខណ្ឌ របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងរបាយការណ៍អធិការកិច្ចតាមប្រធានបទ ដែលរៀបចំដោយនាយកដ្ឋានធានាគុណភាពអប់រំ (EQAD) ផងដែរ។ នេះមានន័យ ថាសាធារណជនដែលបានបើកចូលទៅក្នុង QEMIS នឹងអាចទទួលបានរបាយការណ៍ដែលខ្លួនចង់បាន។

**ប្រព័ន្ធរបាយការណ៍តាមកាលកំណត់**

| **ប្រភេទរបាយការណ៍** | **អ្នកទទួល** | | | |
|---|---|---|---|---|
| របាយការណ៍សាលារៀន | សាលារៀន | DOE | | Q-EMIS |
| របាយការណ៍សង្ខេប | | DOE | | Q-EMIS |
| ការវិភាគប្រចាំឆ្នាំ | | | EQAD | Q-EMIS |

### ៦.២.៣-លទ្ធផលនៃដំណើរការវាយតម្លៃ

សាលារៀននឹងត្រូវបានវាយតម្លៃលើផ្នែកសំខាន់ៗចំនួន៤ ដូចបានរៀបរាប់ខាងលើ។ កម្រិតវិនិច្ឆ័យនៃការវាយតម្លៃមាន៤កម្រិតគឺ ៖ **ល្អឥតខ្ចោះ ល្អ ពេញចិត្ត** និង**មិនពេញចិត្ត**។

*ឧទាហរណ៍អំពីរបៀបប្រើលក្ខណវិនិច្ឆ័យខាងលើ៖

- **ល្អឥតខ្ចោះ** ៖ វិនិច្ឆ័យលើចំណុចខ្លាំងចម្បងៗ ផលសម្រេចល្អណាស់ និងភាពលេចធ្លោនៃការបំពេញការងាររបស់សាលារៀនលើផ្នែកដែលបានវាយតម្លៃ (ឧទហរណ៍៖ ការបោះបង់ការសិក្សាទាប កុមារីទាំងអស់បានបញ្ចប់ការអប់រំចំណេះទូទៅ...) (ត្រូវរកឧទហរណ៍ពីបរិបទក្នុងប្រទេសកម្ពុជា មកគូសបញ្ជាក់)
- **ល្អ** ៖ មានចំណុចខ្លាំងច្រើនជាងចំណុចខ្សោយ។ សាលារៀនធ្វើដំណើរឆ្ពោះទៅរកគោលដៅកំណត់របស់ខ្លួនក្នុងលក្ខណៈស្ថិរភាព និងមានផលសម្រេចល្អកើតពីការខិតខំដើម្បីកែលម្អសាលារៀន

- **ពេញចិត្ត៖** មានទាំងចំណុចខ្លាំង និងចំណុចខ្សោយព្រមគ្នា។ នៅមានការងារមួយចំនួនត្រូវបំពេញបន្ថែម ប៉ុន្តែផ្នែកមួយចំនួនកំពុងឈានឆ្ពោះទៅរកគោលដៅដែលបានកំណត់ជាមួយនឹងផលសម្រេចដំបូងបានកើតជារូបរាង
- **មិនពេញចិត្ត ៖** មានចំណុចអវិជ្ជមានច្រើន និងផលសម្រេចទាប។ សាលារៀនបរាជ័យក្នុងការឈានទៅដល់គោលដៅជាច្រើនដែលបានកំណត់។ ត្រូវចាត់វិធានការណ៍បន្ទាន់ដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ។

### ៦.២.៤-ឧបករណ៍ដែលត្រូវបង្កើត

ដើម្បីអាចអនុវត្តអធិការកិច្ចតាមកាលកំណត់បាន ចាំបាច់ត្រូវបង្កើតឧបករណ៍ជាក់លាក់មួយ ហើយឧបករណ៍ទាំងនេះត្រូវធ្វើការរៀបចំឲ្យមានសង្គតិភាពរវាងការងារអធិការកិច្ច និងក្រុមប្រតិបត្តិករផ្សេងៗ។

ខាងក្រោមនេះជាឧទាហរណ៍ខ្លះ ៖

- សៀវភៅណែនាំស្តីពីការវាយតម្លៃសម្រាប់អធិការ
- លិខិតជូនដំណឹង (ពីអធិការទៅសាលារៀន និងក្រុង ស្រុក ខណ្ឌ)
- សៀវភៅណែនាំស្តីពីការអង្កេត
- កម្រងសំណួរសម្រាប់នាយកសាលារៀន គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងក្រុង ស្រុក ខណ្ឌ
- សៀវភៅណែនាំស្តីពីការធ្វើសម្ភាសន៍
- ឧបករណ៍សម្រាប់វិភាគការវាយតម្លៃ
- សៀវភៅណែនាំស្តីពីការធ្វើរបាយការណ៍
- គោលការណ៍ណែនាំស្តីពី ៖
    - ➢ របៀបធ្វើអធិការកិច្ច
    - ➢ របៀបប្រើឧបករណ៍ថ្មី
    - ➢ របៀបធ្វើរបាយការណ៍លទ្ធផល
    - ➢ របៀបបកស្រាយទំនាក់ទំនងលទ្ធផល។

## ៧-មូលដ្ឋានគតិយុត្តសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ច

ច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិនានា គឺជាការសម្រេចចិត្តផ្នែកនយោបាយក្នុងគោលដៅកែលម្អ និងធានាគុណភាពអប់រំនៅក្នុងប្រព័ន្ធសាលារៀនក្នុងប្រទេសកម្ពុជា។ ដូចនេះកម្រងឯកសារគតិយុត្តទាំងនោះ គឺជាមូលដ្ឋានសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ច។ ភាគច្រើននៃកម្រងឯកសារគតិយុត្តទាំងនោះ ត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការប្រើប្រាស់កម្រងឯកសារគតិយុត្តដែលបានអនុម័តហើយ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ច ហើយគឺជំហានមួយនៃការអនុវត្តបទប្បញ្ញត្តិក្នុងការងារប្រចាំថ្ងៃនៅតាមសាលារៀន ក្នុងប្រទេសកម្ពុជា។ ផ្នែកនេះនឹងពិពណ៌នាអំពីមូលដ្ឋានគតិយុត្តសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ចនៅសាលារៀនក្នុងប្រទេសកម្ពុជា។

## ៧.១-រដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍អន្តរជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា២៦ បានកំណត់ថា ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។ បន្ទាប់ពីការផ្តល់សច្ចាប័ន សន្ធិសញ្ញា និងអនុសញ្ញាទាំងនោះនឹងក្លាយទៅជាច្បាប់ ហើយនឹងអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តក្នុងរឿងក្តីអ្វីមួយ។ ប្រទេសកម្ពុជាបានអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានចែងពីសិទ្ធិនៃការទទួលការអប់រំបឋមសិក្សាដោយឥតគិតថ្លៃ ការអនុវត្តសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការគ្មានអំពើហិង្សានៅក្នុងការអប់រំ។ អនុសញ្ញានេះបានផ្តល់គុណតម្លៃខ្ពស់លើវិស័យអប់រំ និងបានចែងថា មនុស្សវ័យក្មេងត្រូវតែបានលើកទឹកចិត្តដើម្បីឈានទៅដល់កម្រិតខ្ពស់បំផុត នៃការអប់រំទៅតាមសមត្ថភាពរបស់ពួកគេ។

នៅក្នុងអនុសញ្ញានេះមានមាត្រាមួយចំនួនបានផ្តោតលើការអប់រំ និងការទទួលខុសត្រូវរបស់រដ្ឋលើការត្រួតពិនិត្យប្រព័ន្ធសាលារៀន។ នៅក្នុងមាត្រាខាងក្រោមនេះក៏មានសេចក្តីពណ៌នាពីគុណតម្លៃមួយចំនួន និងចំណេះដឹងដែលត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធអប់រំ។ មាត្រា៤៨ ៦៥ ៦៦ ៦៧ និង៦៨ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់អំពីវិស័យអប់រំ ការចូលរៀនដោយសមធម៌ និងរដ្ឋជាអ្នកត្រួតពិនិត្យចំពោះសាលារៀន។

## ៧.២-ច្បាប់ស្តីពីការអប់រំ

ច្បាប់ស្តីពីការអប់រំ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ក្នុងជំពូកទី១ នៃច្បាប់នេះបានចែងអំពីគុណតម្លៃស្មើគ្នា ក៏ដូចជាសិទ្ធិរបស់ជនគ្រប់រូបក្នុងការអប់រំ។ អ្នកសិក្សាទាំងអស់ត្រូវតែទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ[25]។

ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានចែងនៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការអប់រំ។ មាត្រានេះបានចែងថា វិស័យអប់រំ ត្រូវមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃវិស័យអប់រំ ដែលត្រូវបញ្ចូលការត្រួតពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការបំពេញការងារ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ មានភារកិច្ចទទួលខុសត្រូវរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ។

កម្រិតនៃគុណភាព និងប្រសិទ្ធភាពអប់រំ គឺជាប្រធានបទដែលមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីការអប់រំ។ តម្រូវការដែលទាក់ទងនឹងបរិក្ខាការ ការបង្កើតវត្ថុបំណង និងស្ថានភាពជាក់ស្តែងដែលសាលារៀនកំពុងឆ្ពោះទៅរកវត្ថុបំណងទាំងនោះ ក៏ត្រូវបានពិពណ៌នានៅក្នុងជំពូកនេះដែរ។ ម៉្យាងទៀត សាលារៀនក៏តម្រូវឲ្យមានយន្តការស្វ័យវាយតម្លៃ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំផងដែរ។ យន្តការនៃការវាយតម្លៃផ្ទៃក្រៅ ត្រូវបង្កើតឡើងក្នុងគោលបំណងដើម្បីអនុវត្ត និងបំពេញតម្រូវការនៃស្តង់ដារអប់រំ។

---

[25]ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា២

ច្បាប់ស្តីពីការអប់រំ ត្រង់ជំពូកទី៦ បានកំណត់អំពីគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ ដែលក្នុងនោះ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកសាងផែនការគោលសម្រាប់អភិវឌ្ឍវិស័យអប់រំ អនុលោមតាមគោលនយោបាយអប់រំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងទទួលខុសត្រូវចំពោះការអភិវឌ្ឍ និង ការត្រួតពិនិត្យកែសម្រួលគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។

ច្បាប់ស្តីពីការអប់រំ ត្រង់ជំពូកទី៧ បានកំណត់អំពីសិទ្ធិ និងករណីយកិច្ចអប់រំ ដែលកំណត់អំពីសិទ្ធិទទួលបានការអប់រំ សិទ្ធិចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១(មួយ)នៃកម្មវិធីអប់រំចំណេះទូទៅ សិទ្ធិ សេរីភាពខាងជំនឿសាសនាក្នុងការអប់រំ សិទ្ធិ និងករណីយកិច្ចរបស់អ្នកសិក្សា សិទ្ធិ និងករណីយកិច្ចរបស់មាតាបិតា ឬ អ្នកអាណាព្យាបាល សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិកអប់រំ។ ជំពូកនេះក៏បានធានាដល់ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩(ប្រាំបួន)ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។

### ៧.៣-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី៥ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលក្នុងនោះវិស័យអប់រំស្ថិតនៅមុំទី៤ គឺ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សដោយផ្អែកលើអភិបាលកិច្ចល្អជាស្នូល។ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ " វិស័យអាទិភាព៤ " ដូចជាការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងការអនុវត្តគោលនយោបាយប្រជាជន។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ ដែលកាន់តែបើកចំហ តាមរយៈ(១)ការបណ្តុះបណ្តាលពលករឲ្យមានជំនាញ និងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ (២)ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័ន អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងចំណុចទី១ខាងលើ (៣)ការលើកទឹកចិត្តវិស័យឯកជនឲ្យចូលរួមក្នុងកិច្ចការនេះ និង(៤)ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ជាក់ស្តែង នៅក្នុងការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការពង្រឹងគុណភាពប្រជាជន លើកស្ទួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយយុវជនឲ្យទៅជាកម្លាំងចលករដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។ ដើម្បីឆ្លើយតបនឹងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឲ្យកត់សម្គាល់ជាច្រើនក្នុងការលើកកម្ពស់គុណភាព និងជីវភាពរបស់ប្រជាជន ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកែលម្អសូចនាករសង្គម សេដ្ឋកិច្ចសំខាន់ៗក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សុខាភិបាល និងការងារជាដើម។ ទន្ទឹមនឹងនេះ ក្នុងការលើកស្ទួយស្ថានភាពស្ត្រី រាជរដ្ឋាភិបាលបានអនុវត្ត "ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣" ដោយផ្តោតទៅលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈការអភិវឌ្ឍសមត្ថភាពលើផ្នែកចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការបង្កើតលទ្ធភាពដល់ស្ត្រីជាសហគ្រិនក្នុងការទទួលសេវាឥណទានខ្នាតតូច និងមធ្យម។ ក្នុងវិស័យអប់រំ រាជរដ្ឋភិបាលបានកាត់

បន្ថយគម្លាតយេនឌ័រនៅគ្រប់កម្រិត ដោយបានបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេសនារី បង្កើនចំនួនគ្រឹះស្ថានអប់រំទៅដល់មូលដ្ឋាន បង្កើនអន្តេវាសិកដ្ឋាន សម្រាប់សិស្សស្រីជាដើម[26]។

## ៧.៤-អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

អនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ថា នាយកដ្ឋានធានាគុណភាពអប់រំ ទទួលបន្ទុកសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពវិស័យអប់រំ។ នាយកដ្ឋានធានាគុណភាពអប់រំ ក៏ត្រូវពិនិត្យតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា និងបទប្បញ្ញត្តិនៃស្តង់ដារជាតិអប់រំ និងធ្វើរបាយការណ៍សកម្មភាពជូនថ្នាក់ដឹកនាំក្រសួង ដែលជាភារកិច្ចមួយក្នុងចំណោមភារកិច្ចដទៃទៀតរបស់ខ្លួន[27]។

គោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីរៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួង រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពនានាក្នុងក្រសួងអប់រំ យុវជន និងកីឡា និងដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលក្នុងវិស័យអប់រំ យុវជន និងកីឡា។

អនុក្រឹត្យនេះ ត្រូវអនុវត្តនៅគ្រប់ភ្នាក់ងារទាំងអស់នៃថ្នាក់ជាតិ ឬ ថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់សាលារៀន។

អង្គភាពនីមួយៗមានភារកិច្ចជាច្រើន និងភារកិច្ចមួយចំនួនទាក់ទងគ្នាទៅវិញទៅមក ដូចជាការផ្តល់ការគាំទ្រការត្រួតពិនិត្យ និងការពិនិត្យតាមដាន និងការបន្តពិនិត្យតាមដាន ដូចជាការអនុវត្តកម្មវិធីអប់រំជាដើម។ ដូច្នេះ ការញែកឲ្យច្បាស់រវាងនិយ័តភាពការងាររបស់អង្គភាពផ្សេងៗ គឺមានសារៈសំខាន់ណាស់សម្រាប់ការងារធានាគុណភាព និងការធ្វើអធិការកិច្ច។ ជាការសំខាន់ណាស់ផងដែរដែលតម្រូវឱ្យមានការបញ្ជាក់ច្បាស់លាស់ពីការងារដែលមានស្រាប់ និងចំណុចខ្លាំងរបស់នាយកដ្ឋានធានាគុណភាពអប់រំ និងភ្នាក់ងារនានាដែលធ្វើការលើការត្រួតពិនិត្យ អធិការកិច្ច និងការគាំទ្ររួមទាំងនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ។

## ៧.៥-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគោលនយោបាយផ្សេងទៀត

នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអាចរៀបរាប់ពីផ្នែកណានៅក្នុងវិស័យអប់រំដែលត្រូវផ្តល់អាទិភាពខ្ពស់សម្រាប់អំឡុងពេលខាងមុខ។ ផ្នែកទាំងនោះក៏អាចជាចំណុចដៅ និងជាគោលបំណងនៃអធិការកិច្ច ដើម្បីឈានដល់ការអប់រំប្រកបដោយគុណភាពខ្ពស់។ ដូចនេះ ផែនការយុទ្ធសាស្ត្រនាពេលអនាគតក៏អាចពណ៌នាពីផ្នែកដែលត្រូវអភិវឌ្ឍ និងអាចបង្កើតជាមូលដ្ឋានសម្រាប់ការធ្វើអធិការកិច្ចទាំងពីរប្រភេទ គឺអធិការកិច្ចតាមប្រធានបទ និងអធិការកិច្ចតាមកាលកំណត់។

នៅមានគោលនយោបាយ និងគោលការណ៍ណែនាំផ្សេងទៀតជាច្រើនដែលបានរៀបចំ និងអនុម័តមានសារៈសំខាន់សម្រាប់ការងារអធិការកិច្ចផងដែរ ដូចជាគោលនយោបាយស្តីពីសាលាកុមារមេត្រី គោលនយោបាយស្តីពីការអប់រំកុមារពិការ គោលនយោបាយស្តីពីសុខភាពសិក្សា គោលនយោបាយស្តីពីគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ និងគោលការណ៍ណែនាំស្តីពីការផ្តល់អាហារូបករណ៍ជាដើម។

---

[26] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣

[27] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យស្តីពីការរៀបចំ និងកាប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ៨៤.អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩

## ៧.៦-គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥-២០០៩

គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩ បានកំណត់អំពីគោលបំណង និងរចនាសម្ព័ន្ធនៃកម្មវិធីសិក្សា រួមទាំងម៉ោងនៃការបង្រៀនផងដែរ។

គោលបំណងនៃកម្មវិធីសិក្សា គឺអភិវឌ្ឍកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីឱ្យគេក្លាយជាមនុស្ស ពេញលេញ រីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងបញ្ញា ស្មារតី សញ្ចេតនា និងរូបកាយ។ មានទិដ្ឋភាពទូទៅជាច្រើននៃការបង្រៀននិងការរៀន និងគុណភាពក្នុងវិស័យអប់រំ ដែលអាចកំណត់បាននៅក្នុងការធ្វើអធិការកិច្ចជាប្រព័ន្ធ។

ខាងក្រោមនេះជាឧទាហរណ៍ខ្លះនៃសមត្ថភាពដែលសិស្សត្រូវសម្រេចបាន ៖

– មានចំណូលចិត្ត និងស្រឡាញ់ការសិក្សាដើម្បីបម្រើការងារ និងបន្តការសិក្សាពេញមួយជីវិតបាន
– មានចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ ដើម្បីលើកស្ទួយការថែរក្សាសុខភាព ផ្នែកផ្លូវកាយ
– បញ្ញា ស្មារតីរបស់ខ្លួន ហើយចូលរួមចំណែកក្នុងការលើកស្ទួយ ការថែរក្សាសុខភាពក្រុមគ្រួសារ និង សង្គមឲ្យកាន់តែល្អប្រសើរថែមទៀត
– មានសមត្ថភាពគ្រប់គ្រង មានទំនួលខុសត្រូវលើសកម្មភាព លើសេចក្តីសម្រេចចិត្តរបស់ខ្លួន និង មានជំនឿជាក់លើខ្លួនឯង
– មានបំណិនក្នុងការបម្រើការងារ យល់ដឹង និងមានឥរិយាបថវិជ្ជមានចំពោះការងារ និងមានសមត្ថភាព ធ្វើការងារជាមួយអ្នកដទៃប្រកបដោយប្រសិទ្ធភាព និងភាពសុខដុម
– មានសមត្ថភាពក្នុងការពិចារណាថ្លឹងថ្លែង មានស្មារតីទទួលខុសត្រូវមានសីលធម៌ ចេះបែងចែក វិភាគ ដោះស្រាយបញ្ហាក្នុងគ្រួសារ និងសង្គម
– ស្វែងយល់ និងឲ្យតម្លៃដល់អ្នកដទៃ ដល់អរិយធម៌ វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានាដែលអាច ឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធិអ្នកដទៃ និងមានសមធម៌
– ជាពលរដ្ឋសកម្ម មានគំនិតយល់ដឹងជ្រៅជ្រះអំពីការវិវត្តនៃសង្គម ប្រព័ន្ធគ្រប់គ្រង ច្បាប់ទម្លាប់របស់ ប្រទេសកម្ពុជាចេះរក្សា និងលើកស្ទួយតម្លៃជាតិមានស្មារតីស្រឡាញ់ជាតិសាសនា និងព្រះមហាក្សត្រ។

ឯកសារនេះក៏រួមបញ្ចូលផងដែរនូវគោលបំណងផ្សេងទៀតសម្រាប់សាលារៀន ដូចជា កិច្ចសហប្រតិបត្តិការ ជាមួយសង្គមក្នុងគោលបំណងផ្តល់នូវសម្ភាររូបវន្ត និងគ្រឿងបរិក្ខារសម្រាប់កម្មវិធីបំណិនជីវិតមូលដ្ឋានឱ្យ សិស្សបានរៀនទាំងទ្រឹស្តី និងការអនុវត្ត ធ្វើឲ្យប្រាកដថាការអប់រំមានរចនាសម្ព័ន្ធជាប្រព័ន្ធ និងជាសិស្ស មជ្ឈមណ្ឌល[28]។ សាលារៀនក៏ត្រូវផ្តល់ផងដែរនូវឱកាសស្មើគ្នាដល់កុមារា និងកុមារីដើម្បីទទួលបាននូវគ្រប់ សមាសភាគទាំងអស់នៃកម្មវិធីសិក្សា។

## ៧.៧-កម្មវិធីសិក្សា

ក្រៅពីបណ្តុំមុខវិជ្ជា ឬ មុខវិជ្ជា កម្មវិធីសិក្សាទាំងអស់សុទ្ធតែមានខ្លឹមសារដែលពាក់ព័ន្ធទៅនឹងសមត្ថភាព រួមផងដែរ ដូចជាវិចារគណិតវិទ្យា នៅក្នុងមុខវិជ្ជាគណិតវិទ្យា ការធ្វើការជាក្រុមមាននៅក្នុងមុខវិជ្ជាភាសាខ្មែរ ការរៀបចំផែនការ និងការគ្រប់គ្រងមាននៅក្នុងការសិក្សាសង្គម និងការដោះស្រាយចំណោទ មាននៅក្នុង មុខវិជ្ជាវិទ្យាសាស្ត្រ។

[28] ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩។

ជាធម្មតា កម្រិតនៃតម្រូវការ ត្រូវបានកសាងឡើងជាមួយនឹងការវិវត្ត។ ទស្សនវិស័យនៃការធានាគុណភាពបានចាត់ទុកថា កម្មវិធីសិក្សា(កម្មវិធីសិក្សាលម្អិត)គឺជាកត្តាមួយដ៏សំខាន់ពីព្រោះថា ដោយប្រើប្រាស់កម្មវិធីសិក្សាជាចំណុចចាប់ផ្តើម នោះយើងអាចធ្វើការវាស់វែងចំណេះដឹងរបស់សិស្សដែលទាក់ទងទៅនឹងតម្រូវការ និងអាចពិនិត្យមើលលើខ្លឹមសារនៃដំណើរការអប់រំរបស់សាលារៀន ថាតើសាលារៀន និងគ្រូបង្រៀន បានផ្តល់ឱ្យសិស្សនូវឱកាសដើម្បីឈានដល់កម្រិតនៃតម្រូវការដែរឬទេ។ នេះមានន័យថា ការប្រឡងថ្នាក់ជាតិ ក៏ដូចជាក្របខ័ណ្ឌនៃការវាយតម្លៃការងារអធិការកិច្ច អាចត្រូវបានកសាងឡើងដោយយកកម្មវិធីសិក្សាលម្អិតធ្វើជាមូលដ្ឋាន។

### ៧.៨-គ្រូបង្រៀន និងបុគ្គលិកអប់រំ

ច្បាប់ស្តីពីការអប់រំ ត្រង់ជំពូកទី៧ បានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិកអប់រំ។

អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានបង្កើតឡើងក្នុងគោលបំណង៖

- លើកកម្ពស់សីលធម៌របស់គ្រូបង្រៀន
- លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀន និង
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំ។

ភារកិច្ចរបស់គ្រូបង្រៀននៅក្នុងទំនាក់ទំនងអន្តរកម្មជាមួយសិស្ស មាតាបិតា ឬ អាណាព្យាបាល រវាងគ្រូបង្រៀន និងគ្រូបង្រៀន និងបុគ្គលិកមិនបង្រៀន ក៏ត្រូវបានចែងលម្អិតនៅក្នុងអនុក្រឹត្យនេះដែរ។

សិទ្ធិ និងកាតព្វកិច្ចរបស់នាយកសាលារៀន ក៏ជាកត្តាមានសារៈសំខាន់ខ្លាំង និងជាចំណុចស្នូលនៅក្នុងការងារអធិការកិច្ចជាប្រព័ន្ធ។

**បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា នឹងត្រូវពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ឲ្យស្របគ្នាទៅនឹងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន។**